ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅ
# អនុវិទ្យាល័យក្នុងខេត្តស្វាយរៀង

# The Situation of Teacher Professional Standards in Lower-Secondary School in Svay Rieng Province

**ប៉ែន បារាំង**

**PEN BARANG**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០

ឯកទេស ៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅ អនុវិទ្យាល័យក្នុងខេត្តស្វាយរៀង

# The Situation of Teacher Professional Standards in Lower-Secondary School in Svay Rieng Province

**ប៉ែន បារាំង**

**PEN BARANG**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០

ឯកទេស ៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣

គ្រូណែនាំគោល ៖ បណ្ឌិត ឃួយ សុគាន

គ្រូណែនាំរង ៖ បណ្ឌិត ឡៀង សោភទ្រា

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ ប៉ែន បារាំង ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១០ ឯកទេសគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ។

សូមធ្វើការអះអាងថាខ្លឹមសារក្នុងនិក្ខេបបទស្តីពី «**ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង**» គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំពិតប្រាកដដោយមិនបានក្លែងបន្លំ ឬពាក់ព័ន្ធជាមួយនឹងនិក្ខេបបទអ្នកដទៃឡើយ ដើម្បីបំពេញលក្ខខណ្ឌក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ ទិន្នន័យ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវដែលបានលើកឡើងនៅក្នុងនិក្ខេបបទនេះគឺជាទិន្នន័យ និងលទ្ធផលថ្មី ហើយមិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងនិក្ខេបបទរបស់គេឡើយ។

ខ្ញុំបាទសូមសន្យាថា និក្ខេបបទនេះមិនមានការក្លែងបន្លំ និងមិនមានការលួចចម្លងពីនិស្សិត ឬស្នាដៃអ្នកដទៃ។ ក្នុងករណីដែលវិទ្យាស្ថានជាតិអប់រំពិនិត្យឃើញថា មានករណីខាងលើកើតឡើងពិតប្រាកដមែន ខ្ញុំបាទសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃសុក្រ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃ៨ ខែធ្នូ ឆ្នាំ២០២៣

ហត្ថលេខា

**ប៉ែន បារាំង**

# លិខិតបញ្ជាក់

ឈ្មោះ៖ **លោកបណ្ឌិត គួយ សុគាន** ជាគ្រូណែនាំគោល

**ឈ្មោះ៖ លោកបណ្ឌិត ទៀង សោតទ្រា** ជាគ្រូណែនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ម៉ែន ធារ៉ាំង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ នៃវិទ្យាស្ថានជាតិអប់រំពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវលើប្រធានបទ «**ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង**» ពិតប្រាកដមែន។

ថ្ងៃសុក្រ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃ៨ ខែធ្នូ ឆ្នាំ២០២៣

ហត្ថលេខា

............................................ ............................................

**បណ្ឌិត គួយ សុគាន** **បណ្ឌិត ទៀង សោតទ្រា**

គ្រូឧទ្ទេស វជអ គ្រូឧទ្ទេស វជអ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** [illegible] **អយក.**[illegible]

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំរដូវកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ុង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | លាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈុក ច័ន្ទធាយា | នាយកដ្ឋានបវ. | សមាជិក |
| ១២-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ ៤៥០១ អយក.ខ៩ន

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាយ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៉ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សូគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

២២. លោកបណ្ឌិត សោភទ្រា វិទ្យាស្ថានជាតិអប់រំ សមាជិក
២៣. លោក ឡុច ចាន់ថន វិទ្យាស្ថានជាតិអប់រំ សមាជិក
២៤. លោក ចាន់ រ៉ាដា វិទ្យាស្ថានជាតិអប់រំ សមាជិក

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មការគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុត ក្នុងការបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេស ខ្ញុំបាទសូមគោរពថ្លែងអំណរគុណចំពោះបណ្ឌិត **គួយ សុភាន** សាស្ត្រាចារ្យដឹកនាំសរសេរនិក្ខេបបទ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពិនិត្យវាយតម្លៃ ជួយណែនាំ និងផ្ដល់យោបល់ណែនាំល្អៗដល់រូបខ្ញុំបាទក្នុងការសរសេរនិក្ខេបបទស្ដីពី «**ស្ថានភាពនៃការអនុវត្តស្ដង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង**»។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់លោកបណ្ឌិត **ឡៅ សោភទ្រា** សាស្ត្រាចារ្យដឹកនាំរង ដែលតែងតែផ្ដល់នូវកម្លាំងចិត្ត ចំណេះដឹង ចែករំលែកបទពិសោធន៍ល្អៗដែលធ្វើឱ្យរូបខ្ញុំទទួលបានជោគជ័យនាថ្ងៃនេះ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះអ្នកម្ដាយ **នេត សុភាព** ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងដល់រូបកូនឱ្យបានទទួលការសិក្សារហូតរូបកូនក្លាយជាគ្រូបង្រៀនមួយរូបក្នុងថ្ងៃនេះ។ ជាពិសេសឆ្លៀតក្នុងឱកាសនេះអរគុណដល់ឧត្តមភរិយារបស់ខ្ញុំ **យាន សុធាវី** ដែលតែងតែលើកទឹកចិត្ត ផ្ដល់កម្លាំងចិត្តគ្រប់បែបយ៉ាង និងផ្ដល់ពេលវេលាដល់ខ្ញុំក្នុងការសិក្សារៀនសូត្រក្នុងរយៈពេលពីរឆ្នាំនេះ រួមទាំងថវិកាក្នុងការចំណាយផ្សេងៗ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រងវិទ្យាល័យ និងអនុវិទ្យាល័យនានា ដែលបានអនុញ្ញាត និងចូលរួមសហការយ៉ាងល្អប្រសើរធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្ដម លោក/លោកស្រីសាស្ត្រាចារ្យ លោកលោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ការសិក្សានេះមានគោលបំណងសិក្សាអំពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង និងឈ្វេងយល់ពីបញ្ហាប្រឈមនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅវិទ្យាលល័យ និងអនុវិទ្យាល័យចំនួន០៨ ដែលត្រូវបានជ្រើសរើសដើម្បីចុះប្រមូលទិន្នន័យជាមួយក្រុមគោលដៅដែលមានគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន។ អ្នកស្រាវជ្រាវបានធ្វើការសិក្សាស្រាវជ្រាវអំពី ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀងដោយមានគោលបំណង៖ (១)សិក្សាស្វែងយល់ពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង (២)សិក្សាស្វែងយល់ពីបញ្ហាប្រឈមនានាក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង។ ដើម្បីជានាបានលទ្ធផលនៃការស្រាវជ្រាវនេះមានភាពច្បាស់លាស់ និងអាចជឿជាក់បាន អ្នកសិក្សាស្រាវជ្រាវបានប្រើវិធីសាស្ត្រតាមបែប បរិមាណវិស័យ និងប្រមូលទិន្នន័យលើគ្រូបង្រៀនចំនួន១១១នាក់ និងគណៈគ្រប់គ្រងសាលារៀនចំនួន២០នាក់ ដោយនបានជ្រើសរើសចេញពីសាលាវិទ្យាល័យ និងអនុវិទ្យាល័យចំនួន៣៦សាលា ក្នុងខេត្តស្វាយរៀង។ ការវិភាគទិន្នន័យ ដោយកម្មវិធី SPSS ត្រូវបានយកមកប្រើដើម្បីវិភាគទិន្នន័យ។

ជាលទ្ធផលអ្នកស្រាវជ្រាវបានបង្ហាញអំពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនក្នុងខេត្តស្វាយរៀងអនុវត្តបាន «ល្អ» ដែលស្តង់ដាទីមួយ ចំណេះដឹងវិជ្ជាជីវៈ និងស្តង់ដាទីពីរ ការប្រតិបត្តិវិជ្ជាជីវៈអនុវត្តបានក្នុងកម្រិត «ល្អបង្គួរ» ដូចគ្នា។ ចំពោះស្តង់ដាទីបី ការសិក្សាវិជ្ជាជីវៈ បានអនុវត្តបានក្នុងកម្រិត « មធ្យម» ដែលលទ្ធផលនេះតម្រូវឱ្យគ្រប់ភាគីពាក់ព័ន្ធចូលរួមគាំទ្រ ពិនិត្យ តាមដានបន្ថែមទៀតដល់គ្រូបង្រៀនក្នុងការអនុវត្តលើស្តង់ដានេះឱ្យកាន់តែល្អប្រសើរ។ ចំណែកឯស្តង់ដាទីបួនវិញ សីលធម៌វិជ្ជាជីវៈ គឺមានការអនុវត្តបាន «ល្អ»។

ទន្ទឹមនឹងនេះ លទ្ធផល និងបញ្ហាប្រឈមការសិក្សាក៏បានរកឃើញពីដំណោះស្រាយ និងសំណូមពរមួយចំនួនផងដែរ។

# Abstract

The purpose of this study was to study the status of the implementation of Teacher Professional Standards for secondary school teachers in Svay Rieng province and to understand the challenges of its implementation. Eight Upper and Lower Secondary Schools were selected to collect data with the target groups of teachers and school principals. Researchers conducted a study on the situation of the implementation of Teacher Professional Standards for secondary school teachers in Svay Rieng province with the objectives of (1) understanding the situation of the implementation of Teacher Professional Standards for Lower secondary school teachers in Svay Rieng province (2) understand the challenges of implementing Teacher Professional Standards for secondary school teachers in Svay Rieng province. To ensure the results of this research for its were accurate and reliable, the researchers used a quantitative method with collected data for 111 teachers and 20 school principals selected from 36 high schools in Svay Rieng province. SPSS is used as tool for data analysis and result interpretation by using descriptive.

As a result, the research showed the status of the implementation of professional standards for teachers in Svay Rieng province "good", the first standard of professional knowledge and the second standard of professional practice in the "good" level. However, the third standard, professional study, has been implemented at a "moderate" level, which requires all stakeholders to support teachers in implementing this standard better. The fourth standard, professional ethics, applies "well."

At the same time, the results and challenges of the study also found a number of solutions and suggestions.

# មាតិកា

**សេចក្តីប្រកាសអះអាងរបស់បេក្ខជន**.......... i

**លិខិតបញ្ជាក់**.......... ii

**លិខិតឧទ្ទេសនាម**.......... iii

**លិខិតថ្លែងអំណរគុណ**.......... v

**មូលន័យសង្ខេប**.......... viii

Abstract.......... ix

**មាតិកា**.......... x

**បញ្ជីតារាង**.......... xiii

**ជំពូក ១**.......... 1

**សេចក្តីផ្តើម**.......... 1

១.១ លំនាំបញ្ហា.......... 1

១.២ ចំណោទបញ្ហា.......... 3

១.៣ គោលបំណងស្រាវជ្រាវ.......... 4

១.៤ សំណួរស្រាវជ្រាវ.......... 5

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ.......... 5

១.៦ ដែនកំណត់និងវិសាលភាពនៃការស្រាជ្រាវ.......... 6

១.៧ រចនាសម្ព័ន្ធនៃនិក្ខេបបទ.......... 6

**ជំពូក២**.......... 8

**រំព្ញឹកទ្រឹស្តី**.......... 8

២.១ ទ្រឹស្តីនៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន.......... 8

២.១.១ និយមន័យ.......... 8

២.២ រចនាសម្ព័ន្ធស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន.......... 13

២.២.១ ស្តង់ដាទីមួយ ចំណេះដឹងវិជ្ជាជីវៈ.......... 13

២.២.២ ស្តង់ដាទីពីរ ការប្រតិបត្តិវិជ្ជាជីវៈ.......... 14

២.២.៣ ស្តង់ដាទីបី ការសិក្សាវិជ្ជាជីវៈ.......... 14

២.២.៤ ស្តង់ដាទីបួន សីលធម៌វិជ្ជាជីវៈ.......... 15

២.៣ ប្រភេទនៃភាពជាអ្នកដឹកនាំ.......... 18

២.៣.១ ភាពជាអ្នកដឹកនាំកែប្រែមុខមាត់ថ្មី (Transformational leadership) ........ 18
២.៣.២ ភាពជាអ្នកដឹកនាំប្រតិបត្តិការ (Transactional leadership) ........ 19
២.៤ ភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀន ........ 20
២.៥ ការសិក្សាពីមុនទាក់ទងនឹងភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀន ........ 21
២.៦ ក្របខ័ណ្ឌគំនិត ........ 28
**ជំពូក៣** ........ 29
**វិធីសាស្ត្រនៃការស្រាវជ្រាវ** ........ 29
៣.១ ព័ត៌មានទូទៅនៃកម្រងស្រាវជ្រាវ ........ 29
៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ ........ 29
៣.៣ ក្រុមគោលដៅ ........ 30
៣.៤ ទំហំសំណាក ........ 30
៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ ........ 32
៣.៦. ការជ្រើសរើសសំណាក ........ 33
៣.៧ ឧបករណ៍ស្រាវជ្រាវ ........ 33
៣.៨ ការប្រមូលទិន្នន័យ ........ 35
៣.៩ ការវិភាគទិន្នន័យ ........ 36
៣.១០ ក្រមសីលធម៌នៃការស្រាវជ្រាវ ........ 36
**ជំពូក៤** ........ 37
**លទ្ធផល និងការពិភាក្សា** ........ 37
៤.១ ព័ត៌មានទូទៅ ........ 37
**៤.១.១ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀន** ........ 37
**៤.១.២ ព័ត៌មានទូទៅរបស់គ្រូបង្រៀន** ........ 39
៤.២ វិភាគលម្អិតពីសមាសភាគនៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ........ 42
៤.៣ បញ្ហាប្រឈមក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន៖ ........ 50
**ជំពូក ៥** ........ 52
**សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 52
៥.១ សេចក្តីសន្និដ្ឋាន ........ 52

៥.២ សំណូមពរ........................................................................................................53

៥.៣ អនុសាសន៍........................................................................................................53

**ឯកសារយោង**........................................................................................................54

**ឧបសម្ព័ន្ធ**........................................................................................................67

**ឧបសម្ព័ន្ធ »កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ**........................................................67

**ឧបសម្ព័ន្ធ »ខ «កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា**..........................................70

**ស្តង់ដាទី១ ចំណេះវិជ្ជាជីវៈ**........................................................................................................75

**ស្តង់ដាទី២ ការប្រតិបត្តិវិជ្ជាជីវៈ**........................................................................................77

**ស្តង់ដាទី៣ ការសិក្សាវិជ្ជាជីវៈ**........................................................................................78

**ស្តង់ដាទី៤ សីលធម៌វិជ្ជាជីវៈ**........................................................................................80

# បញ្ជីតារាង

តារាង ៣១ ក្រុមគោលដៅ និងអ្នកចូលរួម.៣.

តារាង ៤១ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀន.១.

តារាង ៤២ ព័ត៌មានទូទៅរបស់គ្រូបង្រៀន.១.

តារាង ៤ ១.២.ស្តង់ដាទីមួយ ចំណេះដឹងវិជ្ជាជីវៈ

តារាង ៤ ២.២.ស្តង់ដាទី២ ការប្រតិបត្តិវិជ្ជាជីវៈ

តារាង ៤ ៣.២.ស្តង់ដា ទីបី ការសិក្សាវិជ្ជាជីវៈ

តារាង ៤ ៤.២.ស្តង់ដាទីបួន សីលធម៌វិជ្ជាជីវៈ

តារាង ៤៥ លទ្ធផលវិភាគជារួមលើស្ថានភាពនៃការអនុវត្ត.២.ស្តង់ដាវិជ្ជាជីវៈគ្រូងបង្រៀន

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

វិស័យអប់រំជាកត្តាគន្លឹះមួយក្នុងការអភិវឌ្ឍធនធានមនុស្សដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ដើម្បីធានានិរន្តរភាពក្នុងការអភិវឌ្ឍធនធានមនុស្ស ចាំបាច់ត្រូវធ្វើការអភិវឌ្ឍគ្រូបង្រៀនឱ្យមានសមត្ថភាពពេញលេញ សំដៅជំរុញការអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ គោលការណ៍ឱ្យសម្រេចតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (គោលនយោបាយគ្រូបង្រៀន, ២០១៣)។ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងវិនិយោគលើការអភិវឌ្ឍន៍គ្រូបង្រៀន ដែលជាអាទិភាពដ៏សំខាន់មួយ ដើម្បីសម្រេចបាននូវការផ្លាស់ប្តូរផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងវិស័យអប់រំ ហើយបានយកចិត្តទុកដាក់លើគុណភាពវិស័យអប់រំនៅកម្ពុជាជាវិស័យអាទិភាពទីមួយ ហើយបានដាក់ចេញនូវយុទ្ធសាស្ត្រ បញ្ចកោណដំណាក់កាលទីមួយ ដើម្បីកែប្រែប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ ហើយការអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានកំណត់ថាជាអាទិភាពយុទ្ធសាស្ត្រទីមួយដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការអប់រំប្រកបដោយគុណភាព ដើម្បីធានាបាននូវមូលធនមនុស្សក្នុងការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា (យុទ្ធសាស្ត្របញ្ចកោណ, ២០២៣)។

គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយផ្តល់ចំណេះដឹង បំណិន និងឥរិយាបទដល់មនុស្សជំនាន់ក្រោយ និងជួយឱ្យពួកគេអាចទទួលបានភាពជោគជ័យនៅក្នុងពិភពលោកដែលកំពុងវិវត្តយ៉ាងឆាប់រហ័សនេះ។ គ្រូបង្រៀនជាកត្តាមួយ ដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍប្រទេសជាតិ ជាពិសេសគុណភាពអប់រំ។ គ្រូបង្រៀនជាតួអង្គដ៏សំខាន់ក្នុងការលើកកម្ពស់គុណភាពអប់រំក្នុងថ្នាក់រៀន និងជាឆ្អឹងខ្នងនៃកំណែទម្រង់សាលារៀន និងប្រព័ន្ធអប់រំទាំងមូល។ វិស័យអប់រំកំពុងមានសន្ទុះរីកចម្រើនគួរឱ្យកត់សម្គាល់ដោយសារការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល និងការចូលរួមពីសំណាក់ដៃគូជាតិ និងអន្តរជាតិ។ សាលារៀន និងគ្រូបង្រៀនគ្រប់ភូមិសិក្សាត្រូវបានកសាង និងធានាបានការរៀនសូត្រដោយបរិយាបន្នរបស់

សិស្សានុសិស្សក្នុងក្របខ័ណ្ឌទូទាំងប្រទេស។ ទន្ទឹមនឹងការរីកចម្រើនក្រសួងអប់រំ យុវជន និងកីឡាបាន និងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើគុណភាព និងសមត្ថភាពធនធានមនុស្សដើម្បីធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹងសកលភាវូបនីយកម្មអប់រំទាំងនៅក្នុងតំបន់ និងនៅលើសកលលោក។ គ្រូបង្រៀនជាតួអង្គដ៏សំខាន់ដែលមិនអាចខ្វះបានក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិតាមរយៈការកសាងមូលធនមនុស្ស និងជួយពង្រឹងគុណភាពអប់រំ។ តាមរយៈការកែលម្អកម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីបណ្តុះបណ្តាលគ្រូ និងវគ្គបំប៉នសមត្ថភាពដទៃទៀតជាច្រើន ប្រទេសកម្ពុជាបាននឹងកំពុងពង្រឹងសមត្ថភាពគ្រូបង្រៀនឱ្យដល់កម្រិតអតិបរមា។ ស្របពេលជាមួយគ្នានេះដែរក្រសួងអប់រំបានខិតខំផ្តួចផ្តើមគំនិតកសាងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឡើងសម្រាប់ជាត្រីវិស័យចង្អុលប្រាប់អ្នកអប់រំទាំងអស់ ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូក៏ដូចជាវគ្គវិក្រឹតការនានាដើម្បីធ្វើបច្ចុប្បន្នភាពសមត្ថភាពគ្រូបង្រៀន ឱ្យស្របតាមយុគសម័យបច្ចេកវិទ្យាព័ត៌មាន និងសង្គមដោយផ្អែកលើពុទ្ធិ។ លក្ខណៈសម្បត្តិគ្រូបង្រៀនដែលមានស្តង់ដាវិជ្ជាជីវៈរួមមាន៖ **ស្តង់ដាទី១ មានចំណេះដឹងវិជ្ជាជីវៈ** គឺគ្រូបង្រៀនត្រូវយល់ដឹងអំពីសិស្ស មានចំណេះដឹងខ្លឹមសារមេរៀន យល់ដឹងអំពីរបៀបរៀនរបស់សិស្ស ចំណេះដឹងភាសាបរទេស ព្រមទាំងមានសមត្ថភាពចេះប្រើប្រាស់បច្ចេកវិទ្យា (ITC)។ **ស្តង់ដាទី២ ការប្រតិបត្តិវិជ្ជាជីវៈ** គឺគ្រូបង្រៀនត្រូវធ្វើផែនការបង្រៀន និងពិនិត្យតាមដានវាយតម្លៃលទ្ធផលសិក្សា ការគ្រប់គ្រងបរិស្ថានសិក្សា និងវិធីសាស្ត្របង្រៀន។ **ស្តង់ដាទីបី ការសិក្សាវិជ្ជាជីវៈ** ដោយគ្រូបង្រៀនត្រូវស្វ័យសិក្សា វាយតម្លៃការបង្រៀន អភិវឌ្ឍខ្លួនឯង និងរៀបចំផែនការស្វ័យសិក្សា និងការអភិវឌ្ឍចំណេះដឹង ITC បម្រើឱ្យការបង្រៀនចូលរួមកែលម្អការបង្រៀន ពង្រឹងបំណិនទំនាក់ទំនងការសិក្សាស្រាវជ្រាវ និងពង្រឹងសកម្មភាពសិក្សាវិជ្ជាជីវៈ។ **ស្តង់ដាទី៤ សីលធម៌វិជ្ជាជីវៈ** គឺគ្រូបង្រៀនយកចិត្តទុកដាក់ និងថែរក្សាសិស្សដើម្បីប្រយោជន៍សិស្ស និងសង្គម ប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនដោយស្មារតីទទួលខុសត្រូវខ្ពស់ (ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, ២០១៣)។ ដូច្នេះអ្នកសិក្សាចង់ដឹងពិស្តារអំពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យស្វាយរៀងស្ថិតក្នុងកម្រិតណានាពេលបច្ចុប្បន្ន មានបញ្ហាប្រឈមអ្វីខ្លះ។

## ១.២ ចំណោទបញ្ហា

រាជរដ្ឋាភិបាលបានផ្តល់អាទិភាពក្នុងការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស តាមរយៈការពង្រឹងគុណភាពវិស័យអប់រំ ដែលមានចែងក្នុងមុំទី១នៃ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ (យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤, ២០១៨)។ កត្តាធនធានមនុស្សត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ជាអាទិភាពក្នុងផែនការយុទ្ធសាស្រ្តរបស់ខ្លួន ហើយក៏បានដាក់ចេញនូវចក្ខុវិស័យរយៈពេលវែងដោយប្រែក្លាយទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រាក់ចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ធនធានមនុស្សជាកម្លាំងចលករក្នុងការសម្រេចបំណងប្រាថ្នានេះ ហើយគ្រូបង្រៀនត្រូវបានទទួលស្គាល់និងឱ្យតម្លៃខ្ពស់ថាមានតួនាទី និងភារកិច្ចសំខាន់ក្នុងការកសាងធនធានមនុស្ស និងផ្តល់វិភាគទានដល់ការអភិវឌ្ឍបុគ្គល គ្រួសារ សហគមន៍ និងសង្គមជាតិ និងសកលលោក។ គោលនយោបាយគ្រូបង្រៀនក្នុងឆ្នាំ ២០១៣ មានចក្ខុវិស័យកសាងគ្រូបង្រៀនឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម និងមានគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវ ស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារ ប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។ គោលដៅចំនួនបួនត្រូវបានដាក់ចេញក្នុងគោលនយោបាយគ្រូបង្រៀន (១) ទាក់ទាញនិងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន (២) ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន (៣) ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារជាប់ជាប្រចាំ និង (៤) ធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។

គ្រូបង្រៀនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍកុមារ និងផ្តល់ចំណេះដឹងដើម្បីក្លាយជាធនធានមនុស្សដែលមានការទទួលខុសត្រូវខ្ពស់ និងផលិតភាពក្នុងសង្គម។ គ្រូបង្រៀនផ្តល់ចំណេះដឹង និងគុណតម្លៃដល់កុមារជួយរៀបចំពួកគេសម្រាប់ការអប់រំបន្ថែម និងជីវិតការងារ និងជាអ្នករួមចំណែកដ៏សំខាន់ដល់ការអប់រំ។ បើទោះបីជាវិស័យអប់រំទទួលបានការយកចិត្តទុកដាក់ខ្លាំង និងគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធយ៉ាងណាក៏ដោយក៏នៅតែមានចំណុចដែលត្រូវកែលម្អ និងពង្រឹងបន្ថែមដែលរួមមានភាពជាអ្នក

ដឹកនាំគ្រូបង្រៀន ស្ទីលបង្រៀនមិនមានប្រសិទ្ធភាព និងខ្វះខាតការលើកទឹកចិត្ត។ គុណភាពនៃការរៀនរបស់សិស្សឆ្លុះបញ្ចាំងពីគុណភាពនៃការបង្រៀនរបស់គ្រូហើយជាធម្មតាវាអាស្រ័យលើគុណភាពនៃរចនាបទភាពជាអ្នកដឹកនាំរបស់នាយកសាលានីមួយៗ។ ដោយមើលឃើញពីភាពចាំបាច់នៃការអភិវឌ្ឍន៍ការអប់រំ សកលភាវូបនីយកម្មនៅក្នុងការអប់រំបានក្លាយទៅជាបញ្ហាប្រឈមដ៏ធំមួយនៅក្នុងការអភិវឌ្ឍគុណភាពគ្រូបង្រៀន។ ដោយសារគ្រូបង្រៀនមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជាទើបក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលមានចំនួន០៤ ស្តង់ដារួមមាន៖ ស្តង់ដាទីមួយ គឺគ្រូបង្រៀនមានចំណេះដឹងវិជ្ជាជីវៈ ស្តង់ដាទីពីរ ការប្រតិបត្តិវិជ្ជាជីវៈ ស្តង់ដាទីបី គ្រូបង្រៀនសិក្សាវិជ្ជាជីវៈរបស់ខ្លួន ដើម្បីពង្រឹងចំណេះជំនាញវិជ្ជាជីវៈរបស់ខ្លួនឱ្យទាន់តាមសម័យកាល និងត្រូវតាមកាលៈទេសៈឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស និងស្តង់ដាទីបួនគឺ សីលធម៌វិជ្ជាជីវៈ គឺគ្រូបង្រៀនយកចិត្តទុកដាក់ និងថែរក្សាសិស្សដើម្បីប្រយោជន៍សិស្ស និងសង្គមប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនដោយស្មារតីទទួលខុសត្រូវខ្ពស់។ ដូច្នេះអ្នកសិក្សាមានបំណងចង់សិក្សាឈ្វេងយល់ពិស្តារទៅលើស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យនានាក្នុងខេត្តស្វាយរៀង។

## ១.៣ គោលបំណងនិងគោលបំណង

ជាមួយប្រធានបទ «**ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង**» មានគោលបំណងដូចខាងក្រោម៖

- សិក្សាស្វែងយល់ពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង
- សិក្សាស្វែងយល់ពីបញ្ហាប្រឈមនានាក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីជាមូលដ្ឋានក្នុងការស្វែងរកលទ្ធផលនៃការសិក្សាស្រាវជ្រាវលើប្រធានបទ «**ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង**» សំណួរស្រាវជ្រាវមានដូចខាងក្រោម៖

១. តើស្ថានភាពភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀងមានស្ថានភាពយ៉ាងដូចម្តេចខ្លះ?

២. តើបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យល័យក្នុងខេត្តស្វាយរៀង?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ «**ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង**» គឺមានសារៈសំខាន់ចំនួនបីគឺ៖ ទីមួយ យល់បានពិស្តារពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យនានាក្នុងខេត្តស្វាយរៀង។ សារៈសំខាន់ទីពីរគឺ អាចឈ្វេងយល់ពីបញ្ហាប្រឈមនានាដែលកំពុងកើតមានឡើងចំពោះលោកគ្រូ អ្នកគ្រូដែលកំពុងបង្រៀននៅកម្រិតអនុវិទ្យាល័យចំពោះការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ សារៈសំខាន់ទីបីគឺ អាចឱ្យក្រសួងអប់រំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធអាចដឹងរៀបចំផែនការពង្រឹងស្តង់ដាណាមួយដែលមិនទាន់អាចអនុវត្តបានដើម្បីជួយគាំទ្រដល់គ្រូបង្រៀនឱ្យអាចអនុវត្តបាននូវស្តង់ដាទាំងបួនបានពេញលេញ។

សរុបមកវិញ លទ្ធផលដែលបានមកការសិក្សាស្រាវជ្រាវនេះនឹងជួយបង្កើនគុណភាពរបស់គ្រូបង្រៀន ពង្រឹងសមត្ថភាពរបស់គ្រូបង្រៀនសម្រាប់អភិវឌ្ឍសាលារៀន ដែលនឹងជួយគាំទ្រដល់ការលើកកម្ពស់គុណភាពវិស័យអប់រំនៅកម្ពុជាតាមរយៈការកសាងសមត្ថភាពគ្រូបង្រៀន ដើម្បីឱ្យការអប់រំទទួលបានគុណភាពដែលអាចប្រកួតប្រជែងជាមួយប្រទេសក្នុងតំបន់ក៏ដូចជាសកលលោក។ សេចក្តីសន្និដ្ឋានមួយត្រូវបានរកឃើញដើម្បីបានជាមូលដ្ឋានក្នុងការដាក់ចេញនូវអនុសាសន៍ និងសំណូមពរជូនទៅភាគីពាក់ព័ន្ធលើការងារអប់រំ ព្រោះអាចដឹងពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងយុទ្ធសាស្ត្រ

ថ្មីៗបន្ថែមដើម្បីបំពេញទៅលើចំណុចខ្វះខាត និងអ្វីជាតម្រូវការចាំបាច់របស់គ្រូជាមួយនឹងបញ្ហាប្រឈមដែលបានរកឃើញនៅក្នុងការងារស្រាវស្រាវនេះ។ តាមរយៈការពង្រឹងសមត្ថភាពបន្ថែមទៅលើគុណភាពរបស់គ្រូបង្រៀនជាលទ្ធផលនៃការស្រាវជ្រាវនេះភាគីពាក់ព័ន្ធអាចយកទៅប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ឆ្លុះបញ្ចាំងទៅលើស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលបានដាក់ចេញកន្លងមក។

## ១.៦ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីអំពី **«ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង»** បានកំណត់ដោយមានទីតាំង ពេលវេលា និងទីកន្លែងជាក់លាក់មួយពោលគឺសាលាអនុវិទ្យាល័យនៅក្នុងខេត្តស្វាយរៀងអ្នកដែលចូលរួមក្នុងការសិក្សានេះគឺ គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅអនុវិទ្យាល័យគោលដៅក្នុងខេត្តស្វាយរៀងតែប៉ុណ្ណោះ។

## ១.៧ រចនាសម្ព័ន្ធនៃនិក្ខេបបទ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះបែងចែកចេញជា៖

- **ជំពូក១**៖នេះមាន សេចក្តីផ្តើមរួមមានលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំនត់និងវិសាលភាពនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ដោយនាំយកចំណាប់អារម្មណ៍របស់អ្នកអានទៅកាន់ហេតុផល គោលបំណង និងសារៈសំខាន់នៃការសិក្សា។
- **ជំពូក២៖** រំលឹកទ្រឹស្តីនិយាយអំពីបរិបទនៃការស្រាវជ្រាវដែលឧទ្ទិសដល់ការពិនិត្យឡើងវិញនៃទ្រឹស្តីនៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ផ្តោតលើនិយមន័យនៃស្តង់ដាវិជ្ជាជីវៈ និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន វាផ្តល់ព័ត៌មានពិស្តារអំពីលទ្ធផលស្រាវជ្រាវនានាកន្លងមកទាក់ទងនឹងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គោលនយោបាយអប់រំទាក់ទងនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។
- **ជំពូក៣៖** បង្ហាញពីវិធីសាស្ត្រាស្រាជ្រាវ ការវិភាគទិន្នន័យ និងការវិភាគទ្រឹស្តីដែលពិនិត្យមើលក្របខ័ណ្ឌគំនិតដែលត្រូវបានប្រើសម្រាប់ការសិក្សាស្រាវជ្រាវ និងទ្រឹស្តីពាក់ព័ន្ធស្តីអំពីស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

❖ **ជំពូក៤៖** បង្ហាញពីលទ្ធផលស្រាវជ្រាវនៃការសិក្សា និងបកស្រាយយ៉ាងពិស្តារទៅលើបំណងនៃការស្រាវជ្រាវដោយយោងទៅលើលទ្ធផលនៃការស្រាជ្រាវទ្រឹស្តី និងខ្លឹមសារដែលមានរៀបចំនៅក្នុងកម្រងសំណួរ។

❖ **ជំពូក៥៖** សេចក្តីសន្និដ្ឋានលើប្រធានបទតាមរយៈលទ្ធផលនៃការស្រាវជ្រាវ ការដាក់ចេញជាអនុសាសន៍ និងសំណូមពរនានាជូនទៅភាគីពាក់ព័ន្ធលើការអប់រំ ជាពិសេសអ្នកសរសេររៀបចំគោលនយោបាយអប់រំ ដើម្បីធ្វើយ៉ាងណាពង្រឹងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឱ្យកាន់តែប្រសើរឡើង។

# ជំពូក២

# រំលឹកទ្រឹស្តី

គ្រូបង្រៀនជាឆ្អឹងខ្នងនៃការអប់រំ ដែលមានតួនាទីសំខាន់ក្នុងការផ្តល់នូវគុណភាពនៃការបង្រៀន។ គ្រូបង្រៀនដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងមិនអាចធានាបាននូវនិន្តរភាពគុណភាពរបស់សិស្សបានទេ។ វាចាំបាច់ណាស់ក្នុងការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅគ្រូបង្រៀនដើម្បីឆ្លើយតបទៅនឹងការពង្រឹងគុណភាពនៃវិជ្ជាជីវៈរបស់គ្រូឆ្លុះបញ្ចាំងលទ្ធផលរបស់សិស្ស ព្រោះស្ថានភាពរស់នៅរបស់គ្រូបង្រៀនគឺជាលក្ខខណ្ឌនៃការរៀនរបស់សិស្ស។ គុណភាពនៃការអប់រំ គឺជាគុណភាពនៃគ្រប់វិស័យក្នុងប្រទេសមួយ។ ប្រព័ន្ធអប់រំប្រកបដោយគុណភាពអាចផលិតអ្នកជំនាញវិជ្ជាជីវៈនិងផលិតជំនាញគ្រប់ប្រភេទព្រមទាំងអាចក្លាយជាប្រទេសអភិវឌ្ឍន៍បាន។ ដូច្នេះការកែលម្អគុណភាពនៃការបង្រៀនជាចំណុចអាទិភាព ដើម្បីលើកកម្ពស់គុណភាពនៃវិជ្ជាជីវៈរបស់គ្រូបង្រៀន ហើយទាំងនេះនឹងបានបង្ហាញនៅការងារស្រាវជ្រាវនេះ។

## ២.១ ទ្រឹស្តីនៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

### ២.១.១ និយមន័យ

– **តើស្តង់ដាជាអ្វី ?** ស្តង់ដា គឺជាពាក្យកម្ចីមកពីភាសាបារាំង standard ដែលមានន័យថា និយាម ឬបទដ្ឋាន។ ស្តង់ដា មានន័យថា (១) កម្រិតនៃគុណភាព ឬសមិទ្ធផលដែលសម្រេចបាន (២) អ្វីមួយដែលគេទទួលស្គាល់ជាទូទៅហើយប្រើជារង្វាស់ និយាមឬគំរូនៅក្នុងការវាយតម្លៃប្រៀបធៀប (ជួន ណាត, ១៩១៥)។

ពិតហើយថា ការកំណត់កម្រិតបរិមាណ និងគុណភាពផលិតផលមួយវាអាស្រ័យមួយផ្នែកធំទៅលើបុគ្គល ឬមនុស្សមួយក្រុមដែលគេសន្មតថា "ស្តង់ដា "។ អ្នកខ្លះប្រើពាក្យស្តង់ដា សម្រាប់កំណត់បរិមាណ។ ឧទាហរណ៍ ធ្វើការ៧ម៉ោងក្នុងមួយថ្ងៃជាស្តង់ដាមួយ។ ឯអ្នកខ្លះទៀតប្រើពាក្យស្តង់ដាសម្រាប់កំណត់គុណភាព។ ឧទាហរណ៍ គ្រូបង្រៀនមានគុណភាពលុះត្រាតែមានចំណេះដឹងលើមុខវិជ្ជាឯកទេស

មានទេពកោសល្យក្នុងការបង្រៀន។ ប៉ុន្តែស្តង់ដាគុណភាពពិបាកនឹងកំណត់ណាស់ពោលគឺវាប្រែប្រួលទៅតាមអាជីពប្រភេទផលិតផល និងប្រទេសនីមួយៗ។ ដូច្នេះពាក្យស្តង់ដារត្រូវបានប្រើប្រាស់សម្រាប់កំណត់គុណភាព និងបរិមាណរបស់វត្ថុ ឬសមត្ថភាពរបស់មនុស្សទៅតាមមុខរបរ ឬអាជីពផ្សេងៗគ្នា។ ការកំណត់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនពីប្រទេសមួយទៅប្រទេសមួយផ្អែកលើកត្តាច្រើនដូចជា កត្តាបច្ចេកវិទ្យា សេដ្ឋកិច្ច សង្គម និងវប្បធម៌។ ដោយឡែកស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជាយើងបានកំណត់ជាបួនសមាសភាគគឺៈ(១)ចំណេះដឹងវិជ្ជាជីវៈ (២)ការប្រតិបត្តិវិជ្ជាជីវៈ (៣)ការសិក្សាវិជ្ជាជីវៈ (៤)សីលធម៌វិជ្ជាជីវៈ។ សមាសភាគនីមួយៗមានអនុសមាសភាគជាច្រើន និងនៅក្នុងអនុសមាសភាគនីមួយៗមានសេចក្តីពណ៌នាស្តង់ដាជាច្រើនបន្តទៀត ហើយនៅក្នុងសេចក្តីពណ៌នាស្តង់ដានីមួយៗមានបញ្ជាក់ពីសមត្ថភាពលម្អិតតូចៗសម្រាប់ផ្ទៀងផ្ទាត់សមត្ថភាពស្តែងឡើង។ ទោះបីស្តង់ដាបានលើកឡើងពីសមត្ថភាពសំខាន់ៗជាច្រើន តែយើងនឹងជ្រើសរើសយកតែសមត្ថភាពមួយចំនួនដែលយើងចាត់ទុកថាជាសមត្ថភាពអប្បបរមាប៉ុណ្ណោះឯសមត្ថភាពផ្សេងទៀតនឹងត្រូវលើកយកមកបង្ហាញនាពេលអនាគត។ ជាមួយគ្នានេះយើងក៏មានជំនឿជាក់ផងដែរថាគ្រូបង្រៀនទាំងអស់មានសមត្ថភាពដល់ស្តង់ដារអប្បបរមាហើយ។ ឧទាហរណ៍ការបង្ហាញពីការប្តេជ្ញាចិត្តនិងការចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀន។ ចំណែកឯស្តង់ដាផ្សេងទៀតយើងដឹងថាគ្រូបង្រៀនភាគច្រើនកំពុងធ្វើ។ ឧទាហរណ៍ៈ ផ្តល់បរិស្ថានសិក្សាដែលមានសុវត្ថិភាព និងធ្វើឱ្យសិស្សរៀនអស់ពីសមត្ថភាព។ ឯស្តង់ដារខ្លះទៀតមានតែគ្រូមួយចំនួនតូចទេដែលអាចធ្វើបាន។ ឧទាហរណ៍ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យដើម្បីធ្វើឱ្យការបង្រៀនមានប្រសិទ្ធភាព។

**វិជ្ជាជីវៈ** មានន័យថា មុខតំណែងមុខការរបរសម្រាប់ចិញ្ចឹមជីវិត។ ឧទហរណ៍ វិជ្ជាជីវៈរបស់មន្ត្រីរាជការប្រកបវិជ្ជាជីវៈខាងបង្រៀន (ជួន ណាត, ១៩១៥)។

យោងតាមទ្រឹស្តី (Ingvarson and Rowe, 2007; Bourgonje and Tromp, 2011; Santiago and Benavides, 2009) ស្តង់ដាបង្រៀនល្អគួរតែផ្អែកលើគោលគំនិតណែនាំច្បាស់លាស់ ការបង្រៀនល្អត្រូវមានសុពលភាព និងបញ្ជាក់កស្តុតាងដែលត្រូវប្រមូលអំពីអ្វីដែលគ្រូដឹង និងធ្វើដើម្បីលើកកម្ពស់ការ

រៀនសូត្ររបស់សិស្ស។ ហើយចុងក្រោយកំណត់កម្រិតនៃការអនុវត្ត និងលក្ខណៈវិនិច្ឆ័យដើម្បីធានាបាននូវភាពជឿជាក់ពួកគេក៏គួរពន្យល់ពីរបៀប និងផ្នែកណាដែលគ្រូបង្រៀនគួរកែលម្អជាមួយនឹងពេលវេលា និងផ្តល់ឱកាសសម្រាប់រឿងនេះ។ ទាក់ទងនឹងរចនាសម្ព័ន្ធផ្ទៃក្នុងនៃក្របខ័ណ្ឌស្តង់ដាយើងនឹងសង្ខេបយ៉ាងខ្លីថា តើស្តង់ដាគួរមានលក្ខណៈបែបណាដោយផ្អែកលើអក្សរសិល្ប៍ និងអ្វីដែលយើងបានរកឃើញនៅក្នុងស្តង់ដាវិជ្ជាជីវៈដែលបានជ្រើសរើសទាក់ទងនឹងការកែលម្អគ្រូបង្រៀនស្តង់ដាគួរតែជំរុញគ្រូបង្រៀនឱ្យអនុវត្តជាអ្នកជំនាញលើកកម្ពស់សមត្ថភាពគ្រូបង្រៀននៃការយល់ចិត្ត និងប្រសិទ្ធភាពខ្លួនឯង។ ទាក់ទងនឹងស្តង់ដា «កំណើន និងការអភិវឌ្ឍន៍» គួរតែតម្រឹមសមត្ថភាពពីទស្សនៈនៃការកែលម្អបន្តិចម្តងៗដែលអាចកើតឡើងនៅដំណាក់កាលផ្សេងៗគ្នានៃអាជីពគ្រូបង្រៀន។ ជាងនេះទៅទៀត អក្សរសិល្ប៍ណែនាំថាគ្រូបង្រៀនគួរតែរួមបញ្ចូលជំនាញជីវិតជាក់លាក់ និងទូលំទូលាយ សមត្ថភាពវប្បធម៌ និងសង្គមក៏ដូចជាតម្លៃ (Ingvarson and Rowe, 2007; Bourgonje and Tromp, 2011; Santiago and Benavides, 2009)។ នៅក្នុងស្តង់ដាដែលបានវិភាគហាក់បីដូចជាមានភាពស៊ីសង្វាក់គ្នាខ្លះនៅក្នុងអ្វីដែលគ្រូបង្រៀនត្រូវបានគេរំពឹងថានឹងដឹងនៅពេលពួកគេរីកចម្រើនក្នុងអាជីពរបស់ពួកគេ។ ជាទូទៅគ្រូបង្រៀនដែលមានបទពិសោធន៍កាន់តែច្រើនពួកគេនឹងអាចសម្របខ្លួនបានកាន់តែច្រើន (អូស្ត្រាលី ស្កុតឡេន និង NBPTS [ឧទាហរណ៍ ស្តង់ដាវិជ្ជាជីវៈកុមារភាពមជ្ឈឹមវ័យទូទៅ])។ ស្តង់ដាដែលបានជ្រើសរើសសម្រាប់ការអភិវឌ្ឍន៍វិជ្ជាជីវៈតាមវិធីផ្សេងៗគ្នាដោយមានការគាំទ្រពីឯកសារដែលស្របតាមស្តង់ដាវិជ្ជាជីវៈដែលចាប់ពីការផ្តល់គោលការណ៍ណែនាំសំខាន់ៗរហូតដល់ការបញ្ជាក់ឧទាហរណ៍នៃសកម្មភាព យើងបានកំណត់ចំណុចខាងក្រោមជាផ្នែកសំខាន់ៗដែលគ្របដណ្តប់លើស្តង់ដាទាំងអស់ឬភាគច្រើន៖

- ការធ្វើផែនការ
- បរិយាកាសក្នុងថ្នាក់រៀន
- ការណែនាំ
- ការចូលរួមរបស់សិស្ស និងការរៀនសូត្រសកម្ម
- ធ្វើការជាមួយថ្នាក់ផ្សេងគ្នា (ការបង្រៀនសម្របខ្លួន)

- ទ្រឹស្តីអំពីការរៀន
- ការវាយតម្លៃ
- ប្រើប្រាស់ទិន្នន័យ និងចូលរួមក្នុងការស្រាវជ្រាវ។

ដើម្បីស្វែងយល់ពីរបៀបដែលវិជ្ជាជីវៈរបស់គ្រូបង្រៀន និងចំណេះដឹងរបស់គ្រូបង្រៀនត្រូវបានបង្ហាញនៅក្នុងឯកសារសំខាន់ៗពោលគឺក្របខ័ណ្ឌគុណវុឌ្ឍិ និងស្តង់ដាវិជ្ជាជីវៈដោយបានអនុវត្តតាមវិធីការវិភាគពីរយ៉ាងគឺ វិធីទីមួយមានគោលបំណងស្វែងយល់ថាតើឯកសារទាំងនេះជាអ្វីដោយសង្ខេបនិយមន័យនៃគោលគំនិតសំខាន់ៗទាក់ទងនឹងស្តង់ដា និងក្របខ័ណ្ឌគុណវុឌ្ឍិ និងស្វែងយល់ពីរបៀបដែលក្របខ័ណ្ឌទាំងនេះទាក់ទងគ្នាទៅវិញទៅមកដើម្បីណែនាំវិជ្ជាជីវៈរបស់គ្រូបង្រៀន។ វិធីនេះបានរកឃើញថា សមត្ថភាព គុណវុឌ្ឍិជំនាញ និងលក្ខខណ្ឌពាក់ព័ន្ធផ្សេងទៀតនៅតែខ្វះភាពច្បាស់លាស់។ នេះគឺពាក់ព័ន្ធសម្រាប់ការទទួលស្គាល់ និងការផ្តល់តម្លៃនៃឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការអនុវត្ត។ វិធីទី២ មានគោលបំណងប្រៀបធៀបខ្លឹមសារនៃស្តង់ដាវិជ្ជាជីវៈទាក់ទងនឹងផ្នែកសំខាន់ៗនៃចំណេះដឹងរបស់គ្រូ ដែលផ្តោតលើចំណេះដឹងគរុកោសល្យដូចជាការធ្វើផែនការ ការណែនាំទ្រឹស្តី និងការវាយតម្លៃ។ យើងបានរកឃើញថា ស្តង់ដាវិជ្ជាជីវៈចែករំលែកនូវធាតុមួយចំនួនដែលក្នុងនោះការណែនាំខុសៗគ្នាពីខ្លឹមសារចំណេះដឹងដែលស្តង់ដារកំណត់ថាជាលក្ខណៈវិជ្ជាជីវៈ ដែលទទួលបានជោគជ័យបង្ហាញពីភាពស្រដៀងគ្នាមួយចំនួននៅក្នុងលក្ខណៈទូទៅដូចជា ការពិពណ៌នាអំពីសមត្ថភាពការលើកទឹកចិត្តឱ្យមានភាពចម្រុះក្នុងការអនុវត្ត និងការដោះស្រាយបញ្ហា ការច្នៃប្រឌិតក្នុងការបង្រៀន។ គ្រូដែលមានជំនាញកាន់តែច្រើនពួកគេអាចសម្របខ្លួនបានកាន់តែច្រើនដែលនឹងអាចឆ្លងកាត់ក្របខ័ណ្ឌទាំងនេះ។ នេះគឺជាការរកឃើញគួរឱ្យចាប់អារម្មណ៍ជាងនេះ ប្រសិនបើយើងពិចារណាថា "សមត្ថភាព" ទាក់ទងនឹងសមត្ថភាពរបស់បុគ្គលម្នាក់ក្នុងការដោះស្រាយជាមួយនឹងភាពស្មុគស្មាញ និងការផ្លាស់ប្តូរ។ ដូច្នេះស្តង់ដាវិជ្ជាជីវៈយល់អំពីសមត្ថភាពជាសមត្ថភាពប្រើប្រាស់ និងសម្របចំណេះដឹងតាមកម្រិតខ្ពស់នៃសមត្ថភាពនឹងនាំឱ្យមានការអភិវឌ្ឍខ្លួនឯង និងការឆ្លុះបញ្ចាំងយ៉ាងសំខាន់ដែលហៅថា (meta-competence) (Sultana, 2008)។ ទន្ទឹមនឹងនេះ ការផ្តោតលើសមត្ថភាពរបស់គ្រូក្នុងការសម្របខ្លួន (តាមរយៈការប្រើប្រាស់យុទ្ធសាស្ត្របង្រៀន

ចម្រុះ) ក៏បង្ហាញពីសារៈសំខាន់រួមគ្នាដែលក្របខ័ណ្ឌទាំងនេះដាក់លើសមធម៌។ ការវិភាគនៃសមាសធាតុដែលរួមបញ្ចូល «ចំណេះដឹងវិជ្ជាជីវៈ» បង្ហាញថាស្តង់ដារវិជ្ជាជីវៈផ្តោតលើការជួយផ្តល់ ជំនាញ ចំណេះដឹងទៅជាការអនុវត្ត។ «ចំណេះដឹងអំពីកម្មវិធី» សំដៅលើចំណេះដឹងដែលត្រូវការដោយអ្នកជំនាញដើម្បីសម្រេចបាននូវការប្រើប្រាស់ប្រកបដោយជោគជ័យនៃចំណេះដឹងខ្លឹមសារជាក់លាក់ក្នុងអំឡុងពេលអនុវត្តទាំងចំណេះដឹងខ្លឹមសារជាក់លាក់ និងចំណេះដឹងអំពីកម្មវិធីគឺមានសារៈសំខាន់ណាស់ក្នុងការបែងចែកវិជ្ជាជីវៈ។

## ២.១.២ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

តាមពិតការកំណត់បញ្ញត្តិ ឬការឱ្យនិយមន័យស្តង់ដាមានច្រើនណាស់។ ជួនកាលគេសរសេរពាក្យនៅក្នុងឈ្មោះផ្សេងគ្នាប៉ុន្តែមានន័យដូចគ្នា។ ដូច្នេះយើងកំណត់បញ្ញត្តិធំៗបី នៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនគឺៈ (១)ជាសេចក្តីអធិប្បាយសង្ខេប និងច្បាស់លាស់នូវទិដ្ឋភាពទាំងឡាយណាដែលគ្រូបង្រៀនត្រូវយល់ដឹង និងធ្វើ (២)ជាការបញ្ជាក់ប្រាប់ពីអំពើ ឬសកម្មភាពរបស់គ្រូបង្រៀនដែលអាចអនុវត្តបាន ហើយមានឥទ្ធិពលទៅលើសិស្ស (៣)ជាឧបករណ៍វាស់សមត្ថភាពដែលស្តែងចេញរបស់គ្រូបង្រៀន។ ការកសាងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គឺមិនមែនមានបំណងវាយតម្លៃសមត្ថភាពគ្រូបង្រៀនដើម្បីចាត់ជាប្រភេទ គ្រូល្អឬគ្រូខ្សោយនោះទេពោលគឺយើងមានបំណងលើកស្ទួយការបង្រៀន និងរៀនរបស់គ្រូបង្រៀនសម្រាប់ជួយសម្រួលការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលសិក្សាដែលមានកម្រិតសមស្របអាចទទួលយកបានបើប្រៀបធៀបទៅនឹងស្តង់ដាកម្មវិធីសិក្សាចំណេះទូទៅ។ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនគឺជាឧបករណ៍ដ៏មានសារៈសំខាន់បំផុត និងជាខ្នាតគំរូសម្រាប់អ្នកអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូ និងសម្រាប់ធ្វើផែនការកសាងសមត្ថភាពគ្រូបង្រៀន។ ទៅអនាគតក្រសួងនឹងប្រើប្រាស់ស្តង់ដាសម្រាប់ចេញជាអាជ្ញាប័ណ្ណបង្រៀន និងជាលក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ប្រាក់បៀវត្សដូចនៅប្រទេសអភិវឌ្ឍមួយចំនួន។

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានផលប្រយោជន៍ៈ

- កែលំអការបង្រៀន និងរៀន
- ផ្តល់ចក្ខុវិស័យសម្រាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន

- កែលំអកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន
- រៀបចំផែនការអភិវឌ្ឍន៍សាលារៀន
- ធ្វើឱ្យគ្រូបង្រៀនមានលទ្ធភាព និងមានឱកាសជាច្រើនក្នុងការស្វែងរកសេវា ការងារធ្វើទាំងក្នុងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន
- បង្កើនសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនឱ្យប្រហាក់ប្រហែលប្រទេសក្នុងតំបន់
- ផ្តល់ជាមូលដ្ឋានគ្រឹះដើម្បីដំឡើងឋានន្តរសក្តិ ។

## ២.២ រចនាសម្ព័ន្ធស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

រចនាសម្ព័ន្ធស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានចំនួនបួនស្តង់ដារ៖ (១)ចំណេះដឹងវិជ្ជាជីវៈ (២)ការប្រតិបត្តិវិជ្ជាជីវៈ (៣)ការសិក្សាវិជ្ជាជីវៈ និង (៤)សីលធម៌វិជ្ជាជីវៈ។

### ២.២.១ ស្តង់ដាទីមួយ ចំណេះដឹងវិជ្ជាជីវៈ

គ្រូបង្រៀនគឺអ្នកអ្នកដែលមានចំណេះដឹងវិជ្ជាជីវៈសម្បូរបែប ហើយត្រូវតែដឹងច្បាស់ពីតម្រូវការសិក្សាសមត្ថភាពប្រវត្តិសិក្សារបស់សិស្សច្បាស់លាស់ និងឥរិយាបថរបស់សិស្សម្នាក់ៗហើយក៏យល់ដឹងផងដែរពីស្ថានភាពគ្រួសារ និងកត្តាផ្សេងៗដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស (យេនឌ័រ ពិការភាព និងក្រុមជនជាតិភាគតិច..) ព្រមទាំងយល់ដឹងពីវិធីដោះស្រាយបញ្ហាប្រឈមទាំងនេះ។ គ្រូបង្រៀនត្រូវមានការយល់ដឹងពីគោលនយោបាយអប់រំជាពិសេសគោលដៅអបរំជាតិ និងគោលបំណងអប់រំចំណេះទូទៅហើយពេញចិត្តក្នុងការអនុវត្តនៅសាលារៀន។ គ្រូបង្រៀនយល់ពីទ្រឹស្តីក្នុងការរៀបចំកិច្ចតែងការបង្រៀនដូចជា វត្ថុបំណង វិធីសាស្ត្របង្រៀន និងជ្រើសរើសវិធីវាយតម្លៃលទ្ធផលសិក្សាបានសមស្រប។ គ្រូបង្រៀនយល់ពីខ្លឹមសារកម្មវិធីសិក្សាហើយមានសមត្ថភាពពន្យល់មេរៀនបានច្បាស់លាស់ និងយល់ពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយផ្សេងទៀតក្នុងន័យធ្វើយ៉ាងណាឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន។

គ្រូបង្រៀនត្រូវយល់ពីបរិស្ថានអប់រំក្នុងថ្នាក់រៀន និងក្នុងសហគមន៍ជាពិសេសយល់ពីរបៀបរៀនរបស់សិស្សភាពខុសគ្នារវាងទេពកោសល្យ ល្បឿន និងរបៀបសិក្សាដែលមានឥទ្ធិពលដល់ការសិក្សារបស់

សិស្ស ។ ស្តង់ដាទីមួយ ចំណេះដឹងវិជ្ជាជីវៈមានអនុសមាសភាគចំនួនបីគឺៈ ចំណេះដឹងអំពីសិស្ស ចំណេះដឹងអំពីខ្លឹមសារមេរៀន និងចំណេះដឹងពីរបៀបរៀនរបស់សិស្ស។

### ២.២.២ ស្តង់ដាទីពីរ ការប្រតិបត្តិវិជ្ជាជីវៈ

គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព ស្របតាមកម្មវិធីសិក្សាដោយផ្អែកលើសៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារសិក្សាផ្សេងៗទៀតដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវរៀបចំសម្ភារបង្រៀន និងរៀនដើម្បីរិះរកមធ្យោបាយសម្រេចការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព។ គ្រូបង្រៀនក៏ប្រើប្រាស់វិធីវាយតម្លៃលទ្ធផលសិក្សាផ្សេងៗគ្នាដែលស្របទៅតាមតម្រូវការ និងទេពកោសល្យរបស់សិស្ស។ គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាលអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស ។

គ្រូបង្រៀនផ្តល់ឱ្យសិស្សគ្រប់រូបនូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាព និងលើកទឹកចិត្តសិស្សឱ្យមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវចូលរួមក្នុងការអភិវឌ្ឍសាលារៀនដើម្បីគាំទ្រការសិក្សាសុខុមាលភាពរបស់សិស្ស និងគ្រូបង្រៀនឯទៀត។ គ្រូបង្រៀនត្រូវប្រើប្រាស់វិធីបង្រៀនឱ្យសម្បូរបែបដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេចបានវត្ថុបំណងមេរៀន។ ម្យ៉ាងទៀតគ្រូបង្រៀនគួរមានសមត្ថភាពផ្តល់ជាមធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈការអនុវត្តវិធីបង្រៀនសមស្របសម្បូរបែបដោយបង្កឱកាសឱ្យសិស្សចូលរួមគិតបានល្អិតល្អន់និងដោយច្នៃប្រតិដ្ឋ។ លើសពីនេះទៀតគ្រូបង្រៀនត្រូវចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យបើមានលទ្ធភាពដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។

### ២.២.៣ ស្តង់ដាទីបី ការសិក្សាវិជ្ជាជីវៈ

យើងបានដឹងហើយថាគ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សា។ ដូច្នេះគ្រូបង្រៀនត្រូវតែស្វ័យសិក្សា វាយតម្លៃការបង្រៀនដើម្បីអភិវឌ្ឍខ្លួនឯង

និងប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាមុខវិជ្ជាជីវៈជាប្រចាំស្របតាមជីវភាពរស់នៅជាក់ស្តែង។ គ្រូបង្រៀនត្រូវអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងជាមួយអ្នកផ្សេងៗទៀតនៅក្នុងសហគមន៍។ គ្រូបង្រៀនត្រូវលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការអាន និងស្រាវជ្រាវប្រភពឯកសារផ្សេងៗដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលំអការបង្រៀន និងរៀនហើយត្រូវមានទំនាក់ទំនងល្អជាមួយគ្រូដទៃទៀតក្នុងការសិក្សាវិជ្ជាជីវៈ ។

### ២.២.៤ ស្តង់ដាទីបួន សីលធម៌វិជ្ជាជីវៈ

សីលធម៌វិជ្ជាជីវៈ គឺពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈគ្រូបង្រៀនដែលជារួមមានការប្តេជ្ញាចិត្តបង្រៀនសិស្សប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបដោយគតិបណ្ឌិត និងមានចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ។ គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ចមានវត្តមានជាប្រចាំនៅក្នុងសាលារៀន មានការស្លៀកពាក់សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ។ គាត់គួរតែចូលរួមក្នុងគ្រប់សកម្មភាពទាំងក្នុងនិងក្រៅម៉ោងទាំងអស់របស់សាលារៀនឱ្យបានសមស្របតាមករណីដែលអាចធ្វើបាន។

គ្រូបង្រៀនមានប្រសិទ្ធភាព គឺមិនរើសអើងសិស្សទោះនៅក្នុងកាលៈទេសៈណាក៏ដោយដូចជាបញ្ហាយេនឌ័រ ជនជាតិភាគតិច ពិការភាព ភាពក្រីក្រ និងត្រូវចេះថែទាំសិស្សផ្តល់លទ្ធភាពឱ្យសិស្សប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាពហើយយកចិត្តទុកដាក់ដល់សិស្សឱ្យបានស្មើៗគ្នារួច បង្ហាញពីភាពយុត្តិធម៌ក្នុងការត្រួតពិនិត្យលទ្ធផលសិក្សា។ នៅពេលទាក់ទងជាមួយសិស្សគ្រូបង្រៀនត្រូវមានការគោរពសិស្សដោយមិននិយាយមើលងាយ ឬដាក់ទណ្ឌកម្មពួកគេតាមរបៀបហិង្សាឡើយ។ គ្រូបង្រៀនប្រកាន់ចរិយាសម្បត្តិមានសុជីវធម៌ និងអាកប្បកិរិយាថ្លៃថ្នូរសម្រាប់ធ្វើការសហការជាមួយសហការី និងមាតាបិតាសិស្សដើម្បីផលប្រយោជន៍សិស្សផ្តល់ជាគំរូដល់សិស្សក្នុងការរស់នៅ និងរៀនសូត្របានល្អពិសេសចេះលើកកម្ពស់ស្មារតីសិស្សឱ្យរឹងប៉ឹង និងវិជ្ជមានហើយបង្កើតស្មារតីលះបង់ និងការរួមចំណែកចំពោះសហគមន៍ទាំងមូល។

## ២.៣ ការស្រាវជ្រាវចំណេះដឹងវិជ្ជាជីវៈគ្រូបង្រៀន

មានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងក្នុងការធ្វើការស្រាវជ្រាវលើចំណេះដឹងរបស់គ្រូក្នុងទសវត្សថ្មីៗនេះ។ តាមរយៈការសិក្សាដ៏មានឥទ្ធិពលរបស់លោក Shulman (1986, 1987) បានបញ្ជាក់ថា មានអ្នកស្រាវជ្រាវជាច្រើនបានបង្កើតឡើងនូវភាពខុសគ្នាក្នុងការវិភាគលើចំណេះដឹងរបស់គ្រូបង្រៀនរួមមាន ចំណេះដឹងលើខ្លឹមសារមេរៀន (Content Knowledge) ចំណេះដឹងលើខ្លឹមសារគរុកោសល្យ (Pedagogical Content Knowledge) និងចំណេះដឹងគរុកោសល្យទូទៅ (General Pedagogical Knowledge)។ អ្នកស្រាវជ្រាវបានចាត់ទុកថាចំណេះទាំងនេះអាចត្រូវបានគេទទួលស្គាល់ និងបានរួមចំណែកដល់ការបង្រៀនប្រកបដោយប្រសិទ្ធភាពទៅលើការសិក្សា និងលទ្ធផលសិក្សារបស់សិស្ស។ ជាក់ស្តែងថ្មីៗនេះ ការស្រាវជ្រាវអប់រំបានចាប់ផ្តើមវាយតម្លៃលើចំណេះដឹងរបស់គ្រូបង្រៀនដោយផ្ទាល់ និងបានផ្តល់ភស្តុតាងដែលថាចំណេះដឹង និងជំនាញគឺជាផ្នែកមួយនៃការសម្រេចចិត្តរបស់គ្រូបង្រៀនទាក់ទងនឹងសមិទ្ធិផលរបស់សិស្ស (e.g.,Baumert et al., 2010; Hill, Rowan, & Ball, 2005; Sadler, Sonnert, Coyle, Cook-Smith, & Miller, 2013)។ ការស្រាវជ្រាវប្រសិទ្ធភាពនៃការអប់រំរបស់គ្រូបង្រៀនបានបង្កើតសារៈសំខាន់ការវាស់ស្ទង់ចំណេះដឹងរបស់គ្រូបង្រៀនជាលទ្ធផលនៅផ្សេងៗថាជាដំណាក់កាលនៃការអប់រំគ្រូ (Blömeke, Felbrich, Müller, Kaiser, & Lehmann, 2008)។ តាមពិតមានការសិក្សាជាច្រើនបានសាកល្បងលើចំណេះដឹងរបស់គ្រូបង្រៀន គឺផ្តោតសំខាន់ជាចម្បងលើគ្រូបង្រៀនគណិតវិទ្យា (Ball, Thames, & Phelps, ២០០៨; Baumert et al., 2010; Hill et al., 2005; Schmidt et al., 2007; Tatto et al., 2012) ដូច្នេះវាធ្វើឱ្យមានការយល់ដឹងកាន់តែទូលំទូលាយទាក់ទងនឹងគណិតវិទ្យាដែលជាមុខវិជ្ជាស្នូលរបស់សាលារៀននៅទូទាំងពិភពលោក (Organization for Economic Co-Operation and Development [OECD], 2014)។ ចំណេះដឹងរបស់គ្រូត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយដោយសារតែវាបានរួមចំណែកយ៉ាងសំខាន់ដល់ការបង្រៀនប្រកបដោយប្រសិទ្ធភាព និងការសិក្សារបស់សិស្ស (Darling-Hammond & Bransford, 2007; Gitomer & Zisk, 2015; Grossman & McDonald, 2008; Munby, Russell, & Martin, 2001; Woolfolk Hoy, Davis,

& Pape, 2006)។ ការស្រាវជ្រាវលើជំនាញគ្រូបង្រៀនគូសបញ្ជាក់ពីសារៈចំណេះដឹងជំនាញវិជ្ជាជីវៈរបស់គ្រូបង្រៀនដើម្បីភាពជោគជ័យក្នុងការងារផ្សេងៗ ដែលនេះគឺជាលក្ខណៈធម្មតានៃវិជ្ជាជីវៈគ្រូបង្រៀន (e.g., Berliner, 2001, 2004; Bromme, 1992) ។ ចំណេះដឹងវិជ្ជាជីវៈគ្រូបង្រៀនត្រូវបានគេយកទៅធ្វើជាឯកសារយោងជាច្រើនក្នុងការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ (Shulman, 1987)។ ការចែកថ្នាក់នៃចំណេះដឹងរបស់គ្រូបង្រៀនរបស់គាត់បានជះឥទ្ធិពលយ៉ាងខ្លាំងដល់និយមន័យ ចំណេះដឹងគ្រូបង្រៀន ហើយរាល់ការសិក្សាស្រាវជ្រាវស្តីអំពីចំណេះដឹងគ្រូបង្រៀនគឺត្រូវពឹងលើការចែកថ្នាក់របស់គាត់ ហើយមានមានឥទ្ធិពលលើនិយមន័យនៃប្រភេទចំណេះដឹងរបស់គ្រូ។ ជាពិសេសនៅពេលធ្វើតេស្តទៅលើគ្រូបង្រៀន អ្នកសិក្សាស្រាវជ្រាវបានញែកពីភាពខុសគ្នារវាង ចំណេះដឹងលើខ្លឹមសារមេរៀន (Content Knowledge) ចំណេះដឹងលើខ្លឹមសារគរុកោសល្យ (Pedagogical Content Knowledge) និងចំណេះដឹងគរុកោសល្យទូទៅ (General Pedagogical Knowledge) (see, for example, Baumert et al., 2010; Tatto et al., 2012)។

- ចំណេះដឹងលើខ្លឹមសារមេរៀន (Content Knowledge) គឺជាចំណេះដឹងនៃមុខវិជ្ជាជាក់លាក់និងទាក់ទងនឹងខ្លឹមសារដែលគ្រូត្រូវបង្រៀន។ ចំណេះដឹងលើខ្លឹមសារមេរៀន ត្រូវបានកំណត់ដោយគោលការណ៍សិក្សាក្រោមប្រធានបទផ្សេងៗ (Freeman, 2002)។

- ចំណេះដឹងគរុកោសល្យទូទៅ (General Pedagogical Knowledge) ដែលមិនសំដៅលើចំណេះជំនាញលើមុខវិជ្ជាឡើយ។ បើយោងតាមលោក Shulman (1987) ចំណេះដឹងគរុកោសល្យ គឺសំដៅដល់គោលការណ៍ និងវិធីសាស្ត្រគ្រប់គ្រងថ្នាក់រៀន និងលើក្រុមណាមួយដែលផ្ទេរចំណេះដឹងលើមុខវិជ្ជា ក៏ដូចជាចំណេះដឹងអំពីអ្នកសិក្សាការវាយតម្លៃការរៀន និងបរិបទអប់រំផ្សេងៗ និងរាល់វត្ថុបំណង។ គរុកោសល្យទូទៅនៅតែជាពាក្យបែបវិទ្យាសាស្ត្រដែលត្រូវការការបញ្ជាក់ហើយហាក់នៅទទួលរងឥទ្ធិពលពីទស្សនៈវប្បធម៌ (Hopmann & Riquarts, 1995)។

- ចំណេះដឹងលើខ្លឹមសារគរុកោសល្យ (Pedagogical Content Knowledge) គឺជាប្រភេទចំណេះដឹងដែលមានលក្ខណៈពិសេសសម្រាប់គ្រូបង្រៀន ហើយផ្តែកលើលក្ខណៈដែលគ្រូទាក់ទងនឹងចំណេះដឹង

គរុកោសល្យរបស់ពួកគេ (អ្វីដែលពួកគេដឹងអំពីការបង្រៀន) ទៅនឹងចំណេះដឹងមុខវិជ្ជារបស់ពួកគេ (អ្វីដែលពួកគេដឹងអំពីអ្វីដែលពួកគេបង្រៀន) ។ យោងទៅតាម Shulman (1987) ចំណេះដឹងខ្លឹមសារគរុកោសល្យគឺសំដៅលើការយល់ដឹងអ្នកឯកទេសដែលមានចំណេះដឹងលើគរុកោសល្យ។

## ២.៤ ប្រភេទនៃភាពជាអ្នកដឹកនាំ

### ២.៤.១ ភាពជាអ្នកដឹកនាំកែប្រែមុខមាត់ថ្មី (Transformational leadership)

របនាបទនៃភាពជាអ្នកដឹកនាំផ្លាស់ប្តូរមានវិមាត្រសំខាន់ៗចំនួនបួនដែលត្រូវបរិយាយៈ ឥទ្ធិពលឧត្តមគតិ ការលើកទឹកចិត្តបំផុសគំនិត ការជំរុញបញ្ញា និង ការពិចារណាជាលក្ខណៈបុគ្គល។ នេះបើតាម Than (2014)បានបញ្ជាក់ថា Burns គឺជាមនុស្សដំបូងគេដែលណែនាំភាពជាអ្នកដឹកនាំផ្លាស់ប្តូរដែលជាពិសេសផ្តោតលើមេដឹកនាំនយោបាយ (Aung, 2012)។ Than បានអះអាងថាការកំណត់អត្តសញ្ញាណនៃការផ្លាស់ប្តូរភាពជាអ្នកដឹកនាំមានភាពវិជ្ជមាន ប៉ះពាល់ទាំងអ្នកដឹកនាំ និងអ្នកក្រោមបង្គាប់។ អ្នកដឹកនាំដែលប្រើការដឹកនាំផ្លាស់ប្តូរ រួមចំណែកដល់ការកសាងកំណើននិងការអភិវឌ្ឍនៃអ្នកដើរតាមដើម្បីសម្រេចបានគោលដៅរួម។ Than (2014) បានរៀបរាប់ថា អ្នកដឹកនាំផ្លាស់ប្តូរបានបង្កើតភាពមិនគួរឱ្យជឿការសម្រេចបានលើសពីការរំពឹងទុកឆ្ពោះទៅរកគោលដៅរបស់អ្នកដើរតាម។ ការផ្លាស់ប្តូរ អ្នកដឹកនាំកំណត់ការរំពឹងទុកដ៏លំបាក ហើយទីបំផុតសម្រេចបានផែនការច្រើនជាង គោលដៅដែលបានកំណត់។ Bass(1998) បានបែងចែកភាពជាអ្នកដឹកនាំនៃការផ្លាស់ប្តូរទៅជាបួនទិដ្ឋភាពយ៉ាងលម្អិត។ Idealized Influence ត្រូវបានគេហៅថាភាពជាអ្នកដឹកនាំដែលមានប្រសិទ្ធិភាព ។ អ្នកដែលមានរបៀបដឹកនាំនេះតែងតែត្រូវបានគោរព កោតសរសើរ និងគោរពពីអ្នកក្រោមបង្គាប់របស់ពួកគេ។ អ្នកដឹកនាំបែបនេះគឺជាគំរូដែលមានឥទ្ធិពលលើរបៀបដែលអ្នកក្រោមបង្គាប់ប្រព្រឹត្ត។ អ្នកក្រោមបង្គាប់មេដឹកនាំបែបនេះត្រៀមខ្លួនជាស្រេចដើម្បីប្រកួតប្រជែងភាពរីកចម្រើនសម្រាប់អ្នកដឹកនាំរបស់ពួកគេ។ ការលើកទឹកចិត្តបំផុសគំនិតគឺជាធាតុសំខាន់មួយក្នុងការអភិវឌ្ឍន៍ចក្ខុវិស័យ។ ចក្ខុវិស័យទៅត្រូវបានអភិវឌ្ឍត្រូវមានភាពឆ្លាតវៃ (ជាក់លាក់ វាស់វែងបាន សម្រេចបាន ភាពប្រាកដនិយម និងពេលវេលា។ ទម្រង់ភាពជាអ្នកដឹកនាំបែបនេះចាំបាច់ត្រូវចែករំលែកដល់អ្នកដើរតាមឲ្យបានច្បាស់ជាទូទៅការយល់ដឹង។ ភាពជាអ្នកដឹកនាំប្រភេទនេះគឺ

ត្រូវការជាចាំបាច់នៅពេលបង្កើតថ្មី និងរក្សាភាពជាអ្នកដឹកនាំថាមពលដើម្បីប្រឈមមុខនឹងគំនិតផ្តួចផ្តើមថ្មី។ កម្រិតខ្ពស់នៃកិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងគឺគោលបំណងសំខាន់នៃរចនាបទភាពជាអ្នកដឹកនាំនេះ (Bass & Avolio, 1994)។ អ្នកដឹកនាំការជំរុញបញ្ញាលើកកម្ពស់ការច្នៃប្រតិដ្ឋ និងការច្នៃប្រតិដ្ឋ។ ដោយផ្អែកតាមវិធីដែលមានស្រាប់នៃស្ថានភាពអ្នកដឹកនាំបែបនេះបង្កើតសេណារីយ៉ូផ្សេងៗដើម្បីលើកទឹកចិត្តអ្នកដើរតាមដើម្បីគិតឱ្យបានស៊ីជម្រៅ និងបង្កើតវិធីសាស្ត្រថ្មីក្នុងការទប់ទល់នឹងបញ្ហាប្រឈម (Bas, 1998)។ អ្នកដឹកនាំការពិចារណាជាបុគ្គលបានលើកកម្ពស់ការអភិវឌ្ឍន៍បុគ្គលសម្រាប់អ្នកដើរតាមរបស់ពួកគេដោយផ្អែកលើតម្រូវការជាក់លាក់របស់អ្នកដើរតាម។ អ្នកដឹកនាំបានធ្វើឱ្យអ្នកដើរតាមដោយការរាយបញ្ជីតម្រូវការនិងផ្តល់នូវប្រតិកម្មគាំទ្រចំពោះតម្រូវការដែលបានលើកឡើង (Northouse, 2010)។ អ្នកដើរតាមដែលដឹកនាំដោយអ្នកដឹកនាំប្រភេទនេះគឺអាចធ្វើឱ្យប្រសើរឡើងនូវការអនុវត្តរបស់ពួកគេដោយសារតម្រូវការរបស់ពួកគេត្រូវបានយកមកពិចារណា និងឆ្លើយតប (Bass and Avolio, 1994)។

### ២.៤.២ ភាពជាអ្នកដឹកនាំប្រតិបត្តិការ (Transactional leadership)

Burns (1978) បានបញ្ជាក់ថានៅក្នុងទំនាក់ទំនងរបស់មេដឹកនាំនិងអ្នកដើរតាមមានភាពជាអ្នកដឹកនាំប្រតិបត្តិការតែងតែប្រើ។ Bass(1998) បានរកឃើញថាមានរង្វាន់និងការដាក់ទណ្ឌកម្មជាថ្នូរនឹងការសម្រេចកិច្ចការ ឬបរាជ័យក្នុងការសម្រេចគោលដៅ។ គាត់បែងចែកភាពជាអ្នកដឹកនាំជាបីផ្នែក រួមមានរង្វាន់បន្តការគ្រប់គ្រងដោយករណីលើកលែង(អកម្ម) និងការគ្រប់គ្រងដោយករណីលើកលែង (សកម្ម)។ រង្វាន់ដែលទាក់ទងនឹងភាពជាអ្នកដឹកនាំត្រូវបានគេយល់ថាត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព (Bass, 1998) ។ អ្នកដឹកនាំកំណត់គោលដៅសម្រាប់អ្នកក្រោមបង្គាប់ដើម្បីសម្រេចបានក្នុងរយៈពេលកំណត់មួយ។ អ្នកដឹកនាំមានរង្វាន់សម្រាប់អ្នកក្រោមបង្គាប់នៅពេលដែលពួកគេសម្រេចបាននូវគោលដៅដែលបានកំណត់។ ភាពជាអ្នកដឹកនាំត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងអង្គការជាច្រើន ការគ្រប់គ្រងដោយករណីលើកលែង (អកម្ម) និងការគ្រប់គ្រងដោយករណីលើកលែង (សកម្ម) គឺជាវិមាត្រពីរនៃភាពជាអ្នកដឹកនាំប្រតិបត្តិការ។ នៅក្នុងការគ្រប់គ្រងដោយករណីលើកលែង(សកម្ម) អ្នកដឹកនាំ

យកចិត្តទុកដាក់លើបញ្ហាប្រឈមដែលនឹងកើតឡើង។ អ្នកដឹកនាំប្រភេទនេះសកម្មឆ្លើយតបទៅនឹងបញ្ហាណាមួយ (Marzano, Waters & McNulty, 2005)។

## ២.៥ ភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀន

គោលគំនិតនៃភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយ និងត្រូវបានពិភាក្សាកាន់តែខ្លាំងឡើងក្នុងចំណោមអ្នកអនុវត្ត អ្នកស្រាវជ្រាវ និងអ្នកប្រាជ្ញអប់រំ ជាពិសេសក្នុងវិស័យភាពជាអ្នកដឹកនាំអប់រំ (Murphy, 2005)។ ការរីកចម្រើននៃភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនត្រូវបានសន្មតថាជាតួនាទីរបស់អ្នកដឹកនាំគ្រូបង្រៀនក្នុងការអភិវឌ្ឍន៍ និងកែលម្អសាលារៀន។ ភាពជាអ្នកដឹកនាំរបស់គ្រូមានគោលបំណងលើកកម្ពស់ការសិក្សារបស់សិស្ស និងលទ្ធផលសិក្សារបស់សិស្សរួមទាំងការអភិវឌ្ឍន៍ស្ថាប័នសាលារៀនដើម្បីទាំងអស់គ្នា (Wenner & Campbell, 2017)។ លើសពីនេះ Nguyen, Harris and Ng (2019) បានអះអាងថាភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនបានជួយលើកកម្ពស់គុណភាពបង្រៀន ប្រសិទ្ធភាពសាលារៀន និងការរៀនសូត្ររបស់សិស្ស។

Wenner and Campbell (2017) បានអះអាងថា គ្រូបង្រៀនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរ និងការកែលម្អសាលារៀន។ ក្នុងចំណោមតួនាទីនៅក្រៅថ្នាក់រៀនរួមមានការជួយគ្រូផ្សេងទៀតការផ្តល់កម្មវិធីអភិវឌ្ឍជំនាញសម្រាប់គ្រូផ្សេងទៀតតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) និងការចូលរួមក្នុងគោលនយោបាយ និងការសម្រេចចិត្តមួយចំនួននៅក្នុងសាលា។ ដូច្នេះភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនត្រូវបានគេមើលឃើញថាជាភាពជាអ្នកដឹកនាំសាលារៀន (Muijs, Chapman, & Armstrong, 2013)។ ភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការកសាងសមត្ថភាពរួមដើម្បីជានា និងនិរន្តរភាពសាលារៀន និងការផ្លាស់ប្តូរប្រព័ន្ធរបស់វា (Harris, 2015)។

គោលគំនិតនៃភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនមានថាមពលដោយសារតែសមត្ថភាពរបស់វាក្នុងការលើកកម្ពស់សីលធម៌របស់គ្រូបង្រៀន និងគុណភាពនៃជីវិតការងាររបស់គ្រូតាមរយៈការចូលរួម និងការសហការកាន់តែច្រើន (Frost & Harris, 2003)។ ក្រៅពីនោះភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនផ្តល់អំណាចដល់គ្រូព្រោះគ្រូជាអ្នកផ្សព្វផ្សាយ ការអនុវត្តការបង្រៀនល្អ និងការផ្តួចផ្តើមគំនិត ដូច្នេះបង្កើនការ

ពង្រឹងអំណាចរបស់គ្រូ (Muijs & Harris, ២០០៦)។ គ្រូបង្រៀនដើរតួនាទីសំខាន់ក្នុងការជះឥទ្ធិពលដល់សិស្សដូច្នេះគ្រូបង្រៀនត្រូវតែបង្កើនចំណេះដឹង និងជំនាញរបស់ខ្លួនដើម្បីបង្កើនលទ្ធផលសិស្ស។ លើសពីនេះតួនាទីរបស់គ្រូបង្រៀនក្នុងការផ្តល់មេរៀន ការចែករំលែកចំណេះដឹង និងជំនាញរបស់ពួកគេអាចមានឥទ្ធិពលលើការកែលម្អសាលារៀន ដែលនាំទៅដល់និរន្តរភាពនៃការអនុវត្តរបស់សាលារៀន។ Curtis (2013) បានកំណត់ភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនថាជាតួនាទី និងទំនួលខុសត្រូវច្បាស់លាស់របស់គ្រូដែលមានប្រសិទ្ធភាពដែលគ្រូត្រូវបំពេញក្នុងថ្នាក់រៀនដើម្បីកែលម្អការរៀនសូត្ររបស់សិស្ស លទ្ធផល និងការកែលម្អសាលា។ ក្នុងគោលគំនិតនេះគ្រូបង្រៀនត្រូវបានចាត់ទុកជាអ្នកស្រាវជ្រាវ អ្នកច្នៃប្រតិដ្ឋ អ្នកដឹកនាំគ្រូបង្រៀន និងអ្នកតស៊ូមតិគោលនយោបាយ។ តួនាទី និងទំនួលខុសត្រូវរបស់គ្រូ គឺដើម្បីជ្រើសរើស និងរក្សាគ្រូដែលមានទេពកោសល្យ គាំទ្រគ្រូបង្រៀនផ្សេងទៀតផ្តួចផ្តើមថ្មី។ ភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនជាសកម្មភាពដែលផ្លាស់ប្តូរការបង្រៀន និងការរៀននៅក្នុងសាលាភ្ជាប់សាលារៀន និងសហគមន៍រួមគ្នាក្នុងន័យការរៀនសូត្រហើយធ្វើឱ្យសង្គមរីកចម្រើនប្រកបដោយនិរន្តរភាព និងគុណភាពជីវិតសម្រាប់សហគមន៍។ ភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនជួយសម្រួលសកម្មភាពជាគោលការណ៍សាលាដើម្បីសម្រេចបានជោគជ័យ។

## ២.៦ ការសិក្សាពីមុនទាក់ទងនឹងភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀន

យោងទៅតាមការពិនិត្យទ្រឹស្តីរបស់អ្នកស្រាវជ្រាវកន្លងមក មានការលើកឡើងពីទម្រង់ភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនដែលធ្វើឡើងនៅក្រៅប្រទេសកម្ពុជាដែលទាក់ទងនឹងភាពជាអ្នកដឹកនាំរបស់គ្រូ។ Pounder (2005) បានធ្វើការសិក្សាស្រាវជ្រាវមួយនៅសាកលវិទ្យាល័យ Business School of Lingnan ជាមួយនិស្សិតឆ្នាំចុងក្រោយសិក្សាមុខជំនាញ BBA មានចំនួន 285នាក់ដើម្បីប្រមូលទិន្នន័យក្នុងការសិក្សា។ អ្នកស្រាវជ្រាវក្នុងការសិក្សាបានបានប្រើកម្រងសំណួរភាពជាអ្នកដឹកនាំពហុកត្តា (MLQ)។ ការវិភាគការរកឃើញតាមការស្រាវជ្រាវបានបង្ហាញថាមានការជាប់ទាក់ទងគ្នាយ៉ាងខ្លាំង និងវិជ្ជមានដោយផ្អែកលើពិន្ទុនៃវិមាត្រនៃភាពជាអ្នកដឹកនាំក្នុងថ្នាក់ផ្លាស់ប្តូរ និងផ្នែកនៃថ្នាក់រៀនលទ្ធផលនៃភាពជាអ្នកដឹកនាំការសិក្សាដែលធ្វើឡើងដោយសកលវិទ្យាល័យហុងកុងបានបង្ហាញពីលទ្ធផលនៃការ

ពិភាក្សាលើ ភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀន ហើយតាមការសន្និដ្ឋាន គ្រូបង្រៀនគឺជាអ្នកដឹកនាំ មានទាំងការដឹកនាំផ្លាស់ប្តូរ និងការអនុវត្តថ្នាក់រៀន (Crowther, 1997; Sherrill, 1999)។

ការសន្និដ្ឋានបានសម្រេចចិត្តលើកគ្នារួមចំណែកនៃការអនុវត្តថ្នាក់រៀនដែលជាលទ្ធផលនៃ ការអនុវត្តការផ្លាស់ប្តូរការដឹកនាំរបស់គ្រូ។ វាត្រូវបានសន្និដ្ឋានថាគ្រូមាន សមត្ថភាពបំប្លែងចំណេះដឹងរបស់ខ្លួនឱ្យមានប្រយោជន៍ក្នុងការអនុវត្តន៍នៅក្នុងថ្នាក់រៀន។ ជាក់ស្តែងភាពជាអ្នកដឹកនាំគ្រូបង្រៀនមានទំនាក់ទំនងរវាងការផ្លាស់ប្តូរភាពជាអ្នកដឹកនាំគ្រូបង្រៀន និងលទ្ធផលនៃការអនុវត្តថ្នាក់រៀន។ សិស្សដែលទទួលបានការយល់ឃើញអំពីការដឹកនាំការផ្លាស់ប្តូរដែលបានបង្ហាញក្នុងបរិបទរបស់ការសិក្សារបស់បានបញ្ចប់ការផ្សារភ្ជាប់ជាមួយនឹងលទ្ធផលនៃការអនុវត្តថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។ សិស្សត្រូវបានលើកទឹកចិត្តឱ្យមានការបើកពិព័រណ៍សម្រាប់ការយល់ដឹង និងការប្រាស្រ័យទាក់ទងគ្នានៅថ្នាក់រៀន ដែលធ្វើឱ្យពួកគេពេញចិត្តក្នុងការងារសាលារៀន។ ក្រោមការដឹកនាំ និងការដឹកនាំជាបន្តបន្ទាប់របស់គ្រូបង្រៀននៅក្នុងថ្នាក់រៀនសិស្សបានយល់ច្បាស់អំពីទំនាក់ទំនង និងការប្រាស្រ័យទាក់ទងគ្នានៅក្នុងថ្នាក់រៀន។ ពួកគេបានកោតសរសើរចំពោះសកម្មភាពបង្រៀន និងបានរៀន ហើយបានអនុវត្តនៅក្នុងថ្នាក់រៀនជាមួយ ដោយមានការគាំទ្រពីគ្រូបង្រៀន។ ព្រោះគ្រូប្រើភាពជាអ្នកដឹកនាំ និងបច្ចេកទេសនៃការលើកទឹកចិត្តសិស្ស សិស្សមានអារម្មណ៍លើកទឹកចិត្ត និងកោតសរសើរការផ្តល់ការសិក្សា។ ទោះយ៉ាងណាក៏ដោយ មានការរួបរួមនៃក្រុមគ្រូបង្រៀន និងសិស្សមានកម្រិត។ ជាលទ្ធផលសិស្សមិនបានធ្វើការជាមួយគ្នាបានល្អ ពួកគេមិនទទួលយកគ្នាទៅវិញទៅមកទេ។ ក៏មានខ្លះដែរគ្រូបង្រៀនដែលមានសិទ្ធិអំណាច ដែលមានលក្ខណៈអភិរក្សនិយម និងស្ទាក់ស្ទើរក្នុងការទទួលយកយុទ្ធសាស្ត្រថ្មី ដែលរួមបញ្ចូលសិស្សទាំងអស់ក្នុងសកម្មភាពជាក្រុម។ សិស្សមិនមានអារម្មណ៍ទទួលខុសត្រូវចូលរួម និងលើកទឹកចិត្តក្នុងសកម្មភាពថ្នាក់រៀន ដូច្នេះហើយពួកគេមិនអាចធ្វើជាម្ចាស់លើកិច្ចការនេះបានទេ សកម្មភាពថ្នាក់រៀន។ ការរកឃើញក៏បានបន្ថែមថាសិស្សមិនត្រូវបានអនុញ្ញាតឱ្យបញ្ចេញមតិរបស់ពួកគេឡើយនិងផ្តួចផ្តើមគំនិត។

Karori, Mulewa, Ombuki and Migosi (2013) បានធ្វើការសិក្សាលើឥទ្ធិពលនៃទម្រង់ការដឹកនាំរបស់គ្រូលើការអនុវត្តការប្រឡងនៅសាលាបឋមសិក្សាសាធារណៈ នៅស្រុក Kikuyu ប្រទេសកេន

យ៉ាដែលគំរូសម្រាប់ការសិក្សានេះគឺ ១៥៤នាក់ក្នុងចំណោម ៧៧០ គ្រូបង្រៀន និង ២៧នាក់ ក្នុងចំណោម ៥៥ សាលា។ ការស្រាវជ្រាវបានប្រើកម្រងសំណួរដែលគ្រប់គ្រងដោយខ្លួនឯងជាមួយនឹងការប្រើសំណួរបើក និងសំណួរបិទ។ ការស្រាវជ្រាវបានបង្ហាញថាមានទំនាក់ទំនងយ៉ាងសំខាន់ រវាងភាពជាអ្នកដឹកនាំរបស់គ្រូ និងការអនុវត្តរបស់សិស្ស និងស្ទីលដឹកនាំរបស់គ្រូ ក៏មានឥទ្ធិពលលើសិស្សដែរ។

អ្នកស្រាវជ្រាវបានស្នើឱ្យគ្រូបង្រៀនប្រើការផ្លាស់ប្តូរភាពជាអ្នកដឹកនាំជាងការដឹកនាំបែបប្រតិបត្តិការចាប់តាំងពីលទ្ធផលរបស់សិស្សគឺច្រើនជាង លើសពីការរំពឹងទុកតាមទ្រឹស្តី។ Aung (2014) បានធ្វើការសិក្សាស្រាវជ្រាវអំពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងចំណេះដឹងនៅសាលាអន្តរជាតិ Pan-Asia ក្នុងប្រទេសថៃ។ ការស្រាវជ្រាវលើគ្រូចំនួន ៣៥ នាក់ ក្នុងចំណោម ៤៩ នាក់ មកពីសាលាមត្តេយ្យ ថ្នាក់ទី១-៦ និងថ្នាក់ទី៧-១២សាលាអន្តរជាតិដោយការសិក្សាបានប្រើឧបករណ៍ Multifactor Leadership Questionnaire(MLQ) ។ លទ្ធផលស្រាវជ្រាវបានបង្ហាញថាទម្រង់នៃភាពជាអ្នកដឹកនាំផ្លាស់ប្តូរគឺច្រើនបំផុត ភាពជាអ្នកដឹកនាំដែលពេញចិត្ត បើប្រៀបធៀបទៅនឹងភាពជាអ្នកដឹកនាំតាមបែបប្រតិបត្តិការ។

សរុបមក ការរកឃើញដែលបានមកពីការពិនិត្យឡើងវិញទ្រឹស្តីភាពជាអ្នកដឹកនាំរបស់គ្រូបានបង្ហាញថា ភាពជាអ្នកដឹកនាំផ្លាស់ប្តូរ គឺជាភាពជាអ្នកដឹកនាំទូទៅបំផុតដែលប្រើដោយគ្រូបង្រៀន និងអង្គការនានា ខណៈពេលដែលភាពជាអ្នកដឹកនាំប្រតិបត្តិការត្រូវបានប្រើប្រាស់តិចបំផុត។ ការរកឃើញនៃការសិក្សាផ្សេងទៀតក៏បានបន្ថែមថា គ្រូបង្រៀនបានប្រើភាពជាអ្នកដឹកនាំជាច្រើន លើសពីការផ្លាស់ប្តូរ និងភាពជាអ្នកដឹកនាំប្រតិបត្តិការ។ ទម្រង់ការដឹកនាំទាំងនោះគឺប្រជាធិបតេយ្យ សិទ្ធិអំណាច និង រចនាបទដឹកនាំការិយាធិបតេយ្យ។ លទ្ធផលបានបង្ហាញថារបៀបដឹកនាំបែបប្រជាធិបតេយ្យត្រូវបានប្រើភាគច្រើន ហើយនេះភ្ជាប់ទៅស្ថានភាពសេដ្ឋកិច្ចសង្គមខ្ពស់នៃសាលារៀនដែលជាកន្លែងគ្រូបង្រៀនធ្វើការមានក្របខណ្ឌគោលគំនិតផ្សេងៗគ្នាជាច្រើននៃការដឹកនាំរបស់គ្រូ ប៉ុន្តែជាទូទៅមួយចំនួនរួមមាន:York-Bark and Duke's (2004) framework ដែលកំណត់ជាតុផ្សំសំខាន់ៗចំនួនបួននៃភាពជាអ្នកដឹកនាំរបស់គ្រូ៖

១.ចំណេះដឹង និងជំនាញជាមូលដ្ឋានៈ អ្នកដឹកនាំគ្រូបង្រៀនត្រូវមានការយល់ដឹងស៊ីជម្រៅលើការបង្រៀន និងការរៀន ក៏ដូចជាសមត្ថភាពក្នុងការធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយអ្នកដទៃ។

២. ឱកាសសម្រាប់ភាពជាអ្នកដឹកនាំៈ អ្នកដឹកនាំគ្រូបង្រៀនត្រូវផ្តល់ឱកាសដើម្បីដឹកនាំ ទាំងក្នុង និងក្រៅថ្នាក់រៀន។

៣. ការគាំទ្រ និងការទទួលស្គាល់ៈ អ្នកដឹកនាំគ្រូត្រូវតែទទួលបានការគាំទ្រ និងទទួលស្គាល់ចំពោះការប្រឹងប្រែងជាអ្នកដឹកនាំរបស់ពួកគេ។

៤. ឥទ្ធិពលលើការសិក្សារបស់សិស្សៈ អ្នកដឹកនាំគ្រូបង្រៀនគួរតែមានផលប៉ះពាល់ជាវិជ្ជមានលើការសិក្សារបស់សិស្ស។ Katzenmeyer and Moller's (2009) framework ដែលកំណត់សមាសភាគទាំងប្រាំពីរនៃភាពជាអ្នកដឹកនាំរបស់គ្រូៈ (១)ការយល់ដឹងដោយខ្លួនឯងៈ អ្នកដឹកនាំគ្រូបង្រៀនត្រូវដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ក៏ដូចជារបៀបដឹកនាំផ្ទាល់ខ្លួន។ (២) ការផ្លាស់ប្តូរនាំមុខៈ អ្នកដឹកនាំគ្រូបង្រៀនត្រូវតែអាចកំណត់អត្តសញ្ញាណ និងអនុវត្តការផ្លាស់ប្តូរដែលត្រូវការនៅក្នុងសាលា ឬថ្នាក់រៀន។ (៣)ការប្រាស្រ័យទាក់ទងៈ អ្នកដឹកនាំគ្រូបង្រៀនត្រូវតែជាអ្នកប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ទាំងពាក្យសម្តី និងជាលាយលក្ខណ៍អក្សរ។ (៤)ភាពចម្រុះៈ អ្នកដឹកនាំគ្រូបង្រៀនត្រូវតែអាចធ្វើការប្រកបដោយប្រសិទ្ធភាពជាមួយមនុស្សមកពីមជ្ឈដ្ឋាន និងវប្បធម៌ផ្សេងៗគ្នា។ (៥)គោលការណ៍ណែនាំ និងភាពជាអ្នកដឹកនាំៈ អ្នកដឹកនាំគ្រូបង្រៀនត្រូវមានចំណេះដឹងអំពីគោលការណ៍ណែនាំ និងអាចមានឥទ្ធិពលលើពួកគេ។ (៦)ការកែលម្អជាប្រចាំៈ អ្នកដឹកនាំគ្រូបង្រៀនត្រូវតែប្តេជ្ញាចិត្តក្នុងការធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់ក្នុងការបង្រៀន និងរៀន។(៧)ការរៀបចំដោយខ្លួនឯងៈ អ្នកដឹកនាំគ្រូបង្រៀនត្រូវចេះរៀបចំ និងគ្រប់គ្រងការងាររបស់ពួកគេប្រកបដោយប្រសិទ្ធភាព។ នេះគ្រាន់តែជាឧទាហរណ៍ពីរនៃក្របខណ្ឌគំនិតនៃការដឹកនាំរបស់គ្រូប៉ុណ្ណោះ។ មានក្របខ័ណ្ឌផ្សេងទៀតជាច្រើនដែលត្រូវបានស្នើឡើង ហើយក្របខ័ណ្ឌជាក់លាក់ដែលសមស្របបំផុតនឹងប្រែប្រួលអាស្រ័យលើបរិបទ។ ទោះជាយ៉ាងណាក៏ដោយ ក្របខណ្ឌទាំងអស់នេះចែករំលែកនូវគោលដៅរួមក្នុងការកំណត់អត្តសញ្ញាណជាតុផ្សំសំខាន់ៗនៃភាពជាអ្នកដឹកនាំគ្រូបង្រៀន និងផ្តល់នូវក្របខ័ណ្ឌសម្រាប់ការយល់ដឹង និងអភិវឌ្ឍអ្នក

ដឹកនាំគ្រូបង្រៀន។ បន្ថែមពីលើក្របខណ្ឌគំនិតទាំងនេះ ក៏មានគំរូមួយចំនួននៃការដឹកនាំរបស់គ្រូផងដែរ។ គំរូទាំងនេះផ្តល់នូវការណែនាំជាក់លាក់បន្ថែមទៀតអំពីរបៀបដែលអ្នកដឹកនាំគ្រូបង្រៀនអាចអភិវឌ្ឍ និង អនុវត្តជំនាញភាពជាអ្នកដឹកនាំរបស់ពួកគេ។ គំរូដ៏ល្បីមួយចំនួននៃភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀនរួមមានៈ (១)គំរូអ្នកដឹកនាំគ្រូបង្រៀន ដែលបង្កើតឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍បុគ្គលិកជាតិ (NSDC) (២)គំរូភាពជាអ្នកដឹកនាំរបស់គ្រូ ដែលបង្កើតឡើងដោយសមាគមជាតិនៃនាយកសាលាមធ្យមសិក្សា (NASSP) (៣)គំរូភាពជាអ្នកដឹកនាំរបស់គ្រូ ដែលត្រូវបានបង្កើតឡើងដោយសមាគមអ្នកគ្រប់គ្រងសាលាអាមេរិក (AASA) (៤)គំរូទាំងនេះផ្តល់នូវធនធាន និងឧបករណ៍ជាច្រើនដែលអាចជួយអ្នកដឹកនាំគ្រូបង្រៀនអភិវឌ្ឍជំនាញរបស់ពួកគេ និងប៉ះពាល់ដល់ការសិក្សារបស់សិស្ស។

សរុបមក មិនមាននិយមន័យតែមួយនៃការដឹកនាំរបស់គ្រូបង្រៀននោះទេ ប៉ុន្តែមានក្របខ័ណ្ឌគោលគំនិត និងគំរូមួយចំនួនដែលអាចជួយឱ្យយល់ និងអភិវឌ្ឍអ្នកដឹកនាំគ្រូបង្រៀន។ ក្របខណ្ឌ និងគំរូទាំងនេះអាចផ្តល់ការណែនាំអំពីធាតុផ្សំសំខាន់ៗនៃភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀន ក៏ដូចជាយុទ្ធសាស្ត្រជាក់លាក់សម្រាប់ការអភិវឌ្ឍ និងអនុវត្តជំនាញភាពជាអ្នកដឹកនាំ។ ការអប់រំគឺជាធាតុដែលមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍន៍ប្រទេស ហើយបង្រៀនដើរតួនាទីយ៉ាងសកម្ម និងសំខាន់ក្នុងការរួមចំណែកដល់ការរៀនសូត្រប្រកបដោយគុណភាពដែលកើតចេញពីការអប់រំដែលមានគុណភាព។ វិធីសាស្ត្រផ្តោតលើសិស្សត្រូវបានលើកទឹកចិត្តឱ្យប្រើនៅក្នុងសាលារៀន ដូច្នេះគ្រូបង្រៀនត្រូវតែ ក្លាយជាអ្នកដឹកនាំល្អក្នុងវិស័យអប់រំ ជាពិសេសនៅក្នុងកម្មវិធី Accelerated Learning Program (ALP) ដើម្បីណែនាំសិស្សក្នុងការចូលរួមក្នុងដំណើរការសិក្សា។ ការរៀនសូត្ររបស់សិស្ស លទ្ធផលអាចអាស្រ័យដោយផ្អែកលើរបៀបដឹកនាំរបស់គ្រូ។ ភាពជាអ្នកដឹកនាំរបស់គ្រូអាចឱ្យសិស្សទទួលបាននូវសមត្ថភាពក្នុងការដោះស្រាយជាមួយនឹងឧបសគ្គផ្សេងៗនៅក្នុងជីវិត (Cruz, Matos & Diniz, 2014) ។ ការដឹកនាំរបស់គ្រូក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយផងដែរទៅនឹងលទ្ធផលសិក្សារបស់សិស្ស។ ការសិក្សាថ្មីបានបង្ហាញថាគ្រូដែលមានបទពិសោធន៍ បង្កើតសមិទ្ធផលបន្ថែមទៀតសម្រាប់សិស្ស (Berry, Daughtrey & Wieder, 2010)។

សរុបមកក្របខណ្ឌភាពជាអ្នកដឹកនាំ និងគំរូរបស់គ្រូទាំងបួន មានទិដ្ឋភាពទូទៅដូចបង្ហាញក្នុងតារាងខាងក្រោម៖

| ខ្លឹមសារ | ភាពជាអ្នកដឹកនាំគំរូដោយ Katzenmeyer និង Moller (2001 &2009) | ក្របខណ្ឌភាពជាអ្នកដឹកនាំដោយ York-Barr និង Duke (2004) | គំរូភាពជាអ្នកដឹកនាំដោយ Muijs និង Harris (2003) | គំរូទាំងបួននៃភាពជាអ្នកដឹកនាំដោយ Angelle (2017) |
|---|---|---|---|---|
| តួនាទីក្រៅថ្នាក់រៀន (Roles beyond classroom) | ✓ | ✓ | ✓ | ✓ |
| តួនាទី និងជំនាញក្នុងការណែនាំការអនុវត្ត (Roles and expertise in instructional practices) | ✓ | ✓ | ✓ | ✓ |
| ស្វ័យភាព/ការពង្រឹងអំណាច (Autonomy/ empowerment) | ✓ | ✓ | ✓ | ✓ |
| ឥទ្ធិពលលើអ្នកដទៃ (Influence on others to improve) | ✓ | ✓ | ✓ | |
| ការសហការ (Collaboration | ✓ | ✓ | ✓ | ✓ |
| វិជ្ជាជីវៈ ការអភិវឌ្ឍ (Professional Development) | ✓ | ✓ | ✓ | |
| ការចូលរួម (Participation and engagement) | ✓ | ✓ | ✓ | ✓ |

| | | | | |
|---|---|---|---|---|
| ការរួមចំណែកដល់សហគមន៍ ( Contribution to the community ) | ✓ | ✓ | ✓ | |
| ការទទួលស្គាល់ ( Recognition | ✓ | ✓ | | |
| បរិយាកាសការងារ ( Work environment ) | ✓ | ✓ | | |
| កែលម្អលទ្ធផលសិក្សារបស់សិស្ស ( Improve student outcomes ) | ✓ | ✓ | | |

## សេចក្ដីសន្និដ្ឋាន

ឯកសារនេះបានសិក្សាអំពីនិយមន័យ និងគោលគំនិតនៃការការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនទាំងបួនដែលរួមមាន៖ (១)ចំណេះដឹងវិជ្ជាជីវៈ (២)ការប្រតិបត្តិវិជ្ជាជីវៈ (៣)ការសិក្សាវិជ្ជាជីវៈ និង(៤) សីលធម៌វិជ្ជាជីវៈ។ លើសពីនេះ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនបានជួយដល់គ្រប់ភាគីពាក់ព័ន្ធឱ្យចូលរួមគាំទ្រដល់គ្រូបង្រៀនដើម្បីឱ្យគ្រូបង្រៀនអាចអនុវត្តនូវស្តង់ដាវិជ្ជាជីវគ្រូបង្រៀន ដើម្បីបង្កើនគុណភាពគ្រូបង្រៀន ប្រសិទ្ធភាពការបង្រៀន និងរៀន។ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះត្រូវបានបង្កើតឡើងសម្រាប់ជាត្រីវិស័យចង្អុលប្រាប់អ្នកអប់រំទាំងអស់ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូ ក៏ដូចជាវគ្គវិក្រឹតការនានាដើម្បីធ្វើបច្ចុប្បន្នភាពសមត្ថភាពគ្រូបង្រៀន ឱ្យស្របតាមយុគសម័យបច្ចេកវិទ្យាព័ត៌មាន និងសង្គមដោយផ្អែកលើពុទ្ធិ។ ជាទូទៅ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះនឹងជួយឱ្យគ្រូបង្រៀនក្លាយជាគ្រូបង្រៀនដែលមានគុណភាព មានភាពជាអ្នកដឹកនាំ និងជួយដល់ការរៀន និងលទ្ធផលសិក្សារបស់សិស្ស ក៏ដូចជាលើកកម្ពស់គុណភាពវិស័យអប់រំនៅកម្ពុជា។ គ្រូបង្រៀនត្រូវបានចាត់ទុកថាជាអ្នកជំនាញក្នុងការអនុវត្តការបង្រៀន និងការរៀនក៏ដូចជាជំនាញក្នុងការគ្រប់គ្រងបរិយាកាសសិក្សានៅក្នុងថ្នាក់រៀន។ ជាមួយគ្នានេះដែរ គ្រូបង្រៀនក្លាយជាអ្នកដឹកនាំនៅខាងក្រៅថ្នាក់រៀនដោយសហការជាមួយមិត្តរួមការងារ ដើម្បីធានាដល់លទ្

ផលសិក្សារបស់សិស្ស និងការកែលម្អសាលា។ ឯកសារនេះបានរកឃើញថា ក្របខណ្ឌស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ដែលជួយដល់គ្រូបង្រៀនក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យកាន់តែមានភាពល្អប្រសើរ។ វាជួយដល់អ្នកស្រាវជ្រាវបានយល់ដឹងពីស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន តាមរយៈការកែលម្អការអនុវត្តការបង្រៀន ក៏ដូចជាការកែលម្អការរៀនសូត្ររបស់សិស្ស។ លើសពីនេះផ្អែកលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលបានពិភាក្សា ឯកសារនេះបានផ្តល់ការយល់ដឹងដ៏មានប្រយោជន៍សម្រាប់អ្នកដឹកនាំសាលាដើម្បីចូលរួមពិនិត្យតាមដាន វាយតម្លៃ ទៅលើគ្រូបង្រៀន ដើម្បីធ្វើឱ្យប្រាកដថាគ្រូបង្រៀនបានចូលរួមអនុវត្តស្តង់ដាបានកម្រិតណា ហើយជួបបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្តស្តង់ដានេះ។ ដោយសារគោលគំនិត និយមន័យក្របខណ្ឌ និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានច្រើនជាងបួនសូចនាករ ការស្រាវជ្រាវជាក់ស្តែងបន្ថែមទៀតគឺចាំបាច់ដើម្បីកំណត់បន្ថែមទៀតលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដើម្បីធ្វើយ៉ាងណាឱ្យគ្រូបង្រៀនមានគុណភាព។ បន្ថែមពីលើនេះ ការសិក្សានាពេលអនាគតគឺទាមទារដើម្បីស្វែងយល់ពីប្រសិទ្ធភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងកែលម្អកែលម្អចំណុចខ្វះខាតនៃការអនុវត្ត។

## ២.៧ ក្របខ័ណ្ឌគំនិត

អ្នកស្រាវជ្រាវបានប្រើ «ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន» ដែលមានស្តង់ដាចំនួនបួនដើម្បីយកទៅសិក្សាពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ដែលស្តង់ដាទាំងបួននោះរួមមាន៖

(១)ចំណេះដឹងវិជ្ជាជីវៈ ដែលមានសូចនាកររងចំនួន ០៣ រួមមាន៖ (១.១) ចំណេះដឹងពីសិស្ស (១.២) ចំណេះដឹងខ្លឹមសារមេរៀន និង (១.៣) ចំណេះដឹងពីរបៀបរៀនរបស់សិស្ស

(២)ការប្រតិបត្តិវិជ្ជាជីវៈ មានសូចនាកររងចំនួន ០៣ រួមមាន៖ (២.១) ការធ្វើផែនការ និងការពិនិត្យតាមដាន វាយតម្លៃលទ្ធផលសិក្សា (២.២) ការគ្រប់គ្រងបរិស្ថានសិក្សា និង (២.៣) វិធីបង្រៀន

(៣) ការសិក្សាវិជ្ជាជីវៈ មានសូចនាកររងចំនួន ០២ រួមមាន៖ (៣.១) ស្វ័យសិក្សា និង (៣.២) ការចូលរួមកែលំអការបង្រៀន

(៤) សីលធម៌វិជ្ជាជីវៈ

# ជំពូក៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានរៀបចំឡើង ដោយប្រើទិន្នន័យបែបបរិមាណវិស័យដែលបានយកមកវិភាគដើម្បីស្វែងយល់ពី **«ស្ថានភាពភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង»** បញ្ហាប្រឈមនានាក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

## ៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ

ជាការពិតណាស់នៅគ្រប់គ្រឹះស្ថានសិក្សាទាំងអស់មិនថា គ្រឹះស្ថានសិក្សាបឋមគ្រឹះស្ថានសិក្សាបឋមភូមិ ឬគ្រឹះស្ថានសិក្សាទុតិយភូមិនោះទេសុទ្ធតែត្រូវការនូវធនធានអប់រំដើម្បីរួមចំណែកអភិវឌ្ឍវិស័យអប់រំឱ្យទទួលបានគុណភាព និងប្រសិទ្ធភាពខ្ពស់។ ហេតុដូច្នេះហើយទាមទារឱ្យគ្រូបង្រៀនមានការគ្រប់គ្រង និងការប្រើប្រាស់ធនធានអប់រំទាំងអស់នេះឱ្យបានល្អចំទិសដៅ គោលដៅ ផែនការ វត្ថុបំណងសកម្មភាព តម្លាភាព និងស្របតាមស្ថានភាពក្នុងតំបន់ក៏ដូចជាពិភពលោកផងដែរ។ ការសិក្សាស្រាវជ្រាវនេះអ្នកស្រាវជ្រាវបានជ្រើសរើសយកទីតាំងនៅខេត្តស្វាយរៀងហើយក្នុងនោះរួមមានចំនួន០២ស្រុក និងក្រុងចំនួន០១ ក្នុងចំណោមស្រុកទាំង ០៦ និងក្រុងចំនួន០២។ ស្រុកទាំងពីរក្នុងកិច្ចការស្រាវជ្រាវនេះរួមមាន៖ ១-ស្រុកស្វាយជ្រំ ២-ស្រុកស្វាយទាប និងក្រុងស្វាយរៀង។ ការសិក្សាស្រាវជ្រាវដែលយកខេត្តស្វាយរៀងមកសិក្សានេះត្រូវបានជ្រើសរើសដោយការកំណត់របស់អ្នកសិក្សាស្រាវជ្រាវចេញពីក្នុងចំណោមស្រុកទាំង០៦ និងក្រុងចំនួន០២ ដោយផ្អែកលើកត្តាពេលវេលា និងដោយសារធនធានមានកំណត់ហើយលក្ខខណ្ឌដែលបានជ្រើសរើសក៏បានប្រើវិធីដូចគ្នាដែរ។ អ្នកសិក្សាស្រាវជ្រាវធ្វើការជ្រើសរើសយកសាលាក្នុងស្រុកទាំង០៣នោះ ហើយបានជ្រើសរើសយកតែចំនួន០៧សាលាប៉ុណ្ណោះក្នុងចំណោមសាលាចំនួន៣៦ សាលាក្នុងស្រុកទាំង០៣ និងក្រុងចំនួន០២ រួមមាន៖ ១-ស្រុកស្វាយជ្រំ (វិទ្យាល័យហ៊ុនសែនស្វាយ

ជ្រំ វិទ្យាល័យគោកព្រីងជំនាន់ថ្មី អនុវិទ្យាល័យ ហ៊ុនសែនតាជៃ អនុវិទ្យាល័យ បាសាក់ ២)ស្រុកស្វាយទាប (អនុវិទ្យាល័យខ្វាយ) និង៣-ក្រុងស្វាយរៀង (វិទ្យាល័យហ៊ុនសែនចេក និងវិទ្យាល័យស្វាយរៀង)។

## ៣.៣ ក្រុមគោលដៅ

ការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើគ្រូបង្រៀន និងនាយកដែលកំពុងបម្រើការងារ និងបង្រៀននៅវិទ្យាល័យឬអនុវិទ្យាល័យនានាក្នុងខេត្តស្វាយរៀងដែលចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ដោយឡែកចំពោះគ្រូបង្រៀនអ្នកស្រាវជ្រាវជ្រើសរើសយកលោកគ្រូ អ្នកគ្រូ ដែលបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិដោយមិនគិតពីក្របខណ្ឌនោះទេ។ ចំពោះក្រុមគោលដៅគឺនាយកសាលា គ្រូបង្រៀនវិទ្យាល័យឬអនុវិទ្យាល័យចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩។ ក្នុងនោះនាយកមានចំនួន ២០នាក់ គ្រូបង្រៀនមានចំនួន ១១១នាក់។ មូលហេតុដែលអ្នកសិក្សាមិនបានជ្រើសរើសយកសិស្សក្នុងការចូលរួមក្នុងកិច្ចការស្រាវជ្រាវនេះគឺដោយសារសិស្សានុសិស្សនៅកម្រិតអនុវិទ្យាល័យមានអាយុចន្លោះពី ១៣ ទៅ១៥ឆ្នាំ ដែលការណ៍នេះបង្ហាញថាពួកគាត់នៅក្មេង មិនទាន់អាចយល់បានពីស្តង់ដាវិជ្ជាជីវៈរបស់គ្រូបង្រៀន និងការអនុវត្តស្តង់ដានេះឡើយ ដូច្នេះទើបអ្នកសិក្សាសម្រេចជ្រើសរើសក្រុមគោលដៅតែជាគ្រូបង្រៀន និងគណៈនាយកសាលារៀនតែប៉ុណ្ណោះ ពីព្រោះគ្រូបង្រៀនគឺជាអ្នកបាននឹងកំពុងអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ហើយទស្សនៈយល់ឃើញរបស់គណៈនាយកសាលាក៏មានសារៈសំខាន់ដែលអាចចូលរួមវាយតម្លៃលើសូចនាករស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនតាមរយៈការដឹកនាំ គ្រប់គ្រង និងតាមរយៈការចុះអធិការកិច្ចជាប្រចាំលើគ្រូបង្រៀន។

**តារាង ៣.៣.១ ៖ ក្រុមគោលដៅ និងអ្នកចូលរួម**

| ល.រ | ក្រុមគោលដៅ | ចំនួនអ្នកចូលរួម |
|---|---|---|
| ១ | គណៈគ្រប់គ្រប់គ្រង | ២០ នាក់ |
| ២ | គ្រូបង្រៀនអនុវិទ្យាល័យ | ១១១ នាក់ |
| | សរុប | ១៣១ នាក់ |

## ៣.៤ ទំហំសំណាក

ភាគសំណាកសម្រាប់ការសិក្សាស្រាវជ្រាវនេះរួមមាន គ្រូបង្រៀនដែលកំពុងបង្រៀននៅកម្រិតមធ្យមបឋមភូមិ មានចំនួន១១១នាក់ នាយកមានចំនួន២០នាក់ នៅកម្រិតអនុវិទ្យាល័យមានទីតាំងស្ថិត

ក្នុងខេត្តស្វាយរៀងដែលបានជ្រើសរើសក្នុងចំណោមស្រុកទាំង០៦ ក្រុងចំនួន០២ក្នុងខេត្តស្វាយរៀងតែប៉ុណ្ណោះ។ ការជ្រើសរើសគ្រូបង្រៀនអនុវិទ្យាល័យ និងគណៈគ្រប់គ្រងត្រូវបានធ្វើឡើងដោយចៃដន្យ។ ការស្រាវជ្រាវនេះត្រូវបានចែកជាពីរដំណាក់កាលសំខាន់ៗរួមមានៈ ដំណាក់កាលទីមួយគឺជាការពិនិត្យមើលឯកសារនានាដែលពាក់ព័ន្ធដែលមានស្រាប់ពាក់ព័ន្ធនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ នៅដំណាក់កាលទីមួយនេះអ្នកស្រាវជ្រាវព្យាយាមសិក្សាស្វែងរកឯកសារផ្សេងៗដែលទាក់ទងនឹងប្រធានបទហើយយកវាមកសិក្សាបន្ថែម និងយកវាជាឯកសារយោងផងដែរ។ ដំណាក់កាលទីពីរគឺជាការចុះប្រមូលព័ត៌មានពីអ្នកពាក់ព័ន្ធដោយផ្ទាល់នៅតាមសាលារៀនគោលដៅដែលទទួលបានការអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងដែលនៅក្នុងដំណាក់កាលនេះ កម្រងសំណួរសម្រាប់គ្រូបង្រៀន និងគណៈគ្រប់គ្រងត្រូវបានរៀបចំឡើងសម្រាប់ជាមូលដ្ឋានក្នុងការប្រមូលព័ត៌មាន។ ការយកកម្រងសំណួរទៅប្រមូលព័ត៌មានមានគោលបំណងស្វែងរកព័ត៌មានផ្សេងៗពីភាគីពាក់ព័ន្ធ គឺចង់បានព័ត៌មានពីពួកគាត់ដើម្បីសិក្សាស្វែងយល់ពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង។

| ល.រ | ឈ្មោះសាលា | គណៈគ្រប់គ្រង | គ្រូបង្រៀន |
|---|---|---|---|
| ១ | វិទ្យាល័យស្វាយរៀង | ៤ | ២០ |
| ២ | វិទ្យាល័យហ៊ុន សែនចេក | ៣ | ២០ |
| ៣ | វិទ្យាល័យហ៊ុន សែនស្វាយជ្រំ | ២ | ២០ |
| ៤ | វិទ្យាល័យគោកព្រីង | ២ | ១០ |
| ៥ | វិទ្យាល័យក្រោលគោ | ៣ | ១១ |
| ៦ | អនុវិទ្យាល័យបាសាក់ | ២ | ១០ |
| ៧ | អនុវិទ្យាល័យខ្នាយ | ២ | ១០ |
| ៨ | អនុវិទ្យាល័យតាដែ | ២ | ១០ |
| **សរុប** | | **២០** | **១១១** |

## ៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ

### ៣.៥.១ ការវិភាគកម្រងសំណួរ

វិធីសាស្ត្រនៃការស្រាវជ្រាវគឺការស្រាវជ្រាវតាមបែបបរិមាណវិស័យ ដោយប្រើប្រាស់កម្មវិធី Excel គណនារកតម្លៃ MEAN និងវិភាគតាមកម្មវិធី SPSS ដោយប្រើ Descriptive។ ចំពោះប្រធានបទ «ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនក្នុងខេត្តស្វាយរៀង» ៖ ករណីសិក្សាក្នុងខេត្តស្វាយរៀងអ្នកស្រាវជ្រាវសម្រេចជ្រើសរើសយកវិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យមកធ្វើជាវិធីសាស្ត្រក្នុងការស្រាវជ្រាវដោយផ្អែកទៅលើកម្រងសំណួរសម្រាប់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ។

ទិន្នន័យកម្រងសំណួរនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានត្រួតពិនិត្យ រៀបចំ បែងចែកតាមប្រភេទ និងវិភាគបកស្រាយ។ ទិន្នន័យនៃការវិភាគលើកម្រងសំណួរគឺត្រូវបានបកស្រាយដាក់ចូលក្នុងតារាងទិន្នន័យ (Data Analyze) ដើម្បីសិក្សាពីភាគរយ (Percentage) នៃអ្នកចូលរួមដែលបានចូលរួមបំពេញកម្រងសំណួរ ចំនួននៃសំណាក (Frequency) ហើយរកតម្លៃមធ្យម (Mean) និងពិនិត្យមើលគម្លាតស្តង់ដា (Standard deviation) ចំពោះតម្លៃមធ្យមដែលរកឃើញនោះមានភាពខុសគ្នាកម្រិតណា ហើយអាចទទួលយកបានដែរឬទេ (Statistically significant) ទៅលើស្ថានភាពនៃភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង។ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសកម្មវិធីវិភាគទិន្នន័យ (SPSS) ដើម្បីធានាពីសុពលភាព និងភាពជឿជាក់លើទិន្នន័យ។

នៅក្នុងកម្រងសំណួរបែបបរិមាណវិស័យរបស់ គ្រូបង្រៀន ពីលេខរៀងទី ១ ដល់លេខរៀងទី ២៨ និងគណៈគ្រប់គ្រងសាលារៀន ពីលេខរៀងពីទី១ ដល់លេខរៀងទី ២៨ ដោយប្រើប្រាស់ទម្រង់ Rating Scale របស់ Likert (1932) មានចំនួន ០៥កម្រិតគឺ៖ (១)កម្រិតតិចបំផុត (២)តិច (៣)មធ្យម (៤) ច្រើន និង (៥)ច្រើនបំផុត។ តារាង Rating Scale របស់ Likert (1932)៖

| |
|---|
| [១=កម្រិតតិចបំផុត] , [២=តិច], [៣=មធ្យម] , [៤=ច្រើន], [៥=ច្រើនបំផុត] |

ការកំណត់ពិន្ទុលើតម្លៃមធ្យម គឺយកតាមលំនាំកម្រិតពិន្ទុរបស់ Boonchom Srisaard (Wannatawee, Worakham, & Panya, 2017)

M= 1.00 – 1.50 ទាបបំផុត

M= 1.51 – 2.50 ទាប

M= 2.51 – 3.50 មធ្យម

M= 3.51 – 4.50 ខ្ពស់

M= 4.51 – 5.00 ខ្ពស់បំផុត

## ៣.៦. ការជ្រើសរើសសំណាក

ការសិក្សាស្រាវជ្រាវនេះបានកំណត់រើសយកវិទ្យាល័យចំនួន០៨ ដែលស្ថិតនៅក្នុងស្រុកចំនួន០២ និងក្រុងចំនួន០១ដែលរួមមាន ៖ ទី១-វិទ្យាល័យហ៊ុនសែនស្វាយជ្រំ ២-វិទ្យាល័យហ៊ុនសែនក្រោលគោ ៣-អនុវិទ្យាល័យហ៊ុន សែនតាដៃ ៤-វិទ្យាល័យគោកព្រីង ៥- អនុវិទ្យាល័យខ្លាយ ៦- អនុវិទ្យាល័យ បាសាក់ វិទ្យាល័យហ៊ុន សែនចេកនិង វិទ្យាល័យស្វាយរៀង ការសិក្សាស្រាវជ្រាវនេះជ្រើសរើសយកជាគុសំណាក ទៅលើគ្រូបង្រៀនចំនួន ១១១នាក់ និងនាយកចំនួន ២០នាក់ដែលស្ថិតនៅក្នុងស្រុកទាំង០២ ក្រុងចំនួន ០១ រួមមាន (ស្រុកស្វាយជ្រំ ស្រុករំដួល, ស្រុកស្វាយទាប, និងក្រុងស្វាយរៀង) ក្នុងខេត្តស្វាយរៀង។

## ៣.៧ ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមានឧបករណ៍ច្រើនសម្រាប់យកទៅប្រមូលព័ត៌មាន ដោយឡែកក្នុងការស្រាវជ្រាវនេះ ចាំបាច់ត្រូវសិក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិ នៃឧបករណ៍ប្រមូលព័ត៌មានមួយនេះ។ អ្នកស្រាវជ្រាវបានសម្រេចចិត្តប្រើប្រាស់កម្រងសំណួរសម្រាប់ប្រមូលទិន្នន័យដើម្បីយកមកវិភាគទិន្នន័យ។ ទោះបីជាយ៉ាងនេះក្តីកម្រងសំណួរជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយប្រភេទក្នុងការប្រមូលទិន្នន័យពីអ្នកឆ្លើយតបបានយ៉ាងច្រើនប្រកបដោយប្រសិទ្ធភាព (Cohen, Manion & Morinion,2007)។

**កម្រងសំណួរសម្រាប់គ្រូ**

**ផ្នែកទី១៖** ព័ត៌មានទូទៅក្នុងផ្នែកនេះមាន០៨សំណួរដែលសួរលើចំណុចដូចជា៖ (១) ឈ្មោះសាលា (២)ភេទ (៣)អាយុ (៤)កម្រិតវប្បធម៌ (៥)វគ្គបណ្តុះបណ្តាលគ្រូរូបមន្ត (៦)បង្រៀនថ្នាក់ទី(៧) សិក្សាវគ្គខ្លីៗ និង(៨)បទពិសោធបង្រៀន។

**ផ្នែកទី២៖** អំពីការសិក្សាស្រាវជ្រាវក្នុងផ្នែកនេះមាន៖

I.ការគ្រប់គ្រងផ្អែកលើចំណេះដឹងឯកទេស មានចំនួន ០៩សូចនាករ

II.ការប្រតិបត្តិវិជ្ជាជីវៈមានចំនួន ០៨សូចនាករ

III.ការសិក្សាវិជ្ជាជីវៈ (ការសិក្សាស្រាវជ្រាវ)មានចំនួន ០៧សូចនាករ

IV.សីលធម៌វិជ្ជាជីវៈមានចំនួន ០៤សូចនាករ

**ផ្នែកទី៣៖បញ្ហាប្រឈមមាន៖ (១)**ការគ្រប់គ្រងផ្អែកលើចំណេះដឹងឯកទេស (២) ការប្រតិបត្តិវិជ្ជាជីវៈ (៣) ការសិក្សាវិជ្ជាជីវៈ (៤) សីលធម៌វិជ្ជាជីវៈ

**ផ្នែកទី៤៖សំណូមពរ**

**កម្រងសំណួសម្រាប់គណៈគ្រប់គ្រង**

កម្រងសំណួសម្រាប់គណៈគ្រប់គ្រង ចែកចេញជា៖

**ផ្នែកទី១៖**ព័ត៌មានទូទៅក្នុងផ្នែកនេះមានចំនួន ០៥សំណួរដែលសួរលើចំណុចដូចជា៖ (១) ឈ្មោះ សាលា (២)ភេទ(៣)អាយុ(៤)កម្រិតវប្បធម៌ (៥)វគ្គបណ្តុះបណ្តាលនាយក

**ផ្នែកទី២៖** អំពីការសិក្សាស្រាវជ្រាវក្នុងផ្នែកនេះមាន៖

I.ការគ្រប់គ្រងផ្អែកលើចំណេះដឹងឯកទេស មានចំនួន ០៩សូចនាករ

II.ការប្រតិបត្តិវិជ្ជាជីវៈមានចំនួន ០៨សូចនាករ

III.ការសិក្សាវិជ្ជាជីវៈ (ការសិក្សាស្រាវជ្រាវ)មានចំនួន ០៧សូចនាករ

IV.សីលធម៌វិជ្ជាជីវៈមានចំនួន ០៤សូចនាករ

**ផ្នែកទី៣៖បញ្ហាប្រឈមមាន៖ (១)**ការគ្រប់គ្រងផ្អែកលើចំណេះដឹងឯកទេស (២) ការប្រតិបត្តិវិជ្ជាជីវៈ (៣) ការសិក្សាវិជ្ជាជីវៈ (៤) សីលធម៌វិជ្ជាជីវៈ

**ផ្នែកទី៤៖សំណួមពរ**

កម្រងសំណួរដែលបានរៀបចំឡើងនេះទទួលបានការណែនាំពិភាក្សា និងផ្តល់យោបល់ជាប្រចាំពីសាស្ត្រាចារ្យណែនាំ។ ក្រោយពីបានពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ និងការណែនាំកែតម្រូវរបស់សាស្ត្រាចារ្យណែនាំរួចមកកម្រងសំណួរនេះត្រូវបានពិនិត្យនិងកែលម្អជាចុងក្រោយ ខ្លឹមសារនៃឧបករណ៍នេះរៀបចំឡើងយោងទៅលើឯកសារនានាដែលធ្លាប់បានសិក្សាស្រាវជ្រាវកន្លងមកពាក់ព័ន្ធ និងស្ទីលនៃភាពជាអ្នកដឹកនាំរបស់គ្រូ។ ដោយឡែកការស្រាវជ្រាវនេះ បានផ្តោតទៅលើតែភាពជាអ្នកដឹកនាំរបស់គ្រូនៅកម្រិតមធ្យមសិក្សាបឋមភូមិ ដែលអ្នកស្រាវជ្រាវបានកំណត់យកសូចនាករសំខាន់មួយចំនួនៗរួមមាន៖

## ៣.៨ ការប្រមូលទិន្នន័យ

បន្ទាប់ពីបានបង្កើតកម្រងសំណួររួច និងទទួលបានការត្រួតពិនិត្យពីសាស្ត្រាចារ្យណែនាំរួចមក អ្នកស្រាវជ្រាវក៏ធ្វើលិខិតស្នើពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងដើម្បីចុះប្រមូលទិន្នន័យនៅតាមសាលារៀនគោលដៅនីមួយៗដូចដែលបានកំណត់។ ម្យ៉ាងទៀតក្រោយពីទទួលបានលិខិតពីវិទ្យាស្ថានជាតិអប់រំ ដំបូងអ្នកស្រាវជ្រាវបានទៅជួបថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងដើម្បីសុំការសហការពាក់ព័ន្ធនិងការស្រាវជ្រាវនេះ ហើយជាលទ្ធផលខាងរដ្ឋបាលមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងបានអនុញ្ញាតឱ្យអ្នកស្រាវជ្រាវបានចុះស្រាវជ្រាវតាមគោលដៅសាលាដែលបានកំណត់។ បន្ទាប់ពីបានទៅសុំការសហការពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តរួចហើយអ្នកស្រាវជ្រាវបានចុះទៅវិទ្យាល័យនានាតាមគោលដៅ ដែលបានកំណត់ដោយបានប្រគល់លិខិតអនុញ្ញាតជូនគណៈគ្រប់គ្រងដើម្បីសុំការអនុញ្ញាតចុះស្រាវជ្រាវ។ ក្រោយពេលទៅដល់សាលានីមួយៗអ្នកសិក្សាស្រាវជ្រាវបានទៅសុំការសហការពីគណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ ហើយបន្ទាប់ពីមានការយល់ព្រមពីគណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូរួចមកអ្នកស្រាវជ្រាវបានចែកកម្រងសំណួរទៅដល់លោកគ្រូអ្នកគ្រូក៏ដូចជា គណៈគ្រប់គ្រងសាលារៀនជួយបំពេញដោយការជ្រើសរើសទៅតាមភាពពិតជាក់ស្តែង នៃកម្រងសំណួរស្របទៅតាមស្ថានភាពពិតជាក់ស្តែងនៃការអនុវត្ត និងដឹកនាំកន្លងមករបស់សាលារបស់ខ្លួន។ ការបំពេញកម្រងសំណួរនេះមានរយៈ

ពេល៣០នាទីហើយក្រោយពីការបំពេញចម្លើយរបស់លោកគ្រូ អ្នកគ្រូ រួចរាល់អ្នកស្រាវជ្រាវក៏បានប្រមូលកម្រងសំណួរដែលមានចម្លើយរបស់គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន ដើម្បីយកមកបញ្ចូលក្នុងប្រព័ន្ធ SPSS និង MS-Excel ដើម្បីវិភាគ។ ការប្រមូលទិន្នន័យនេះនឹងអាចឱ្យអ្នកស្រាវជ្រាវប្រមូលបានព័ត៌មានដ៏មានប្រយោជន៍សម្រាប់ប្រធានបទ **«ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង»**។

## ៣.៩ ការវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបានជាដំបូងនឹងត្រូវយកមកបញ្ចូលក្នុងប្រព័ន្ធកម្មវិធី (Excel ដោយគណនារកតម្លៃ Mean និងតាមកម្មវិធី SPSS សម្រាប់ប្រៀបធៀបអថេរដើម្បីឱ្យការកត់ត្រាទិន្នន័យមានភាពរហ័សនិងមានភាពងាយស្រួលក្នុងការទាញយកព័ត៌មានមករកភាគរយដើម្បីបកស្រាយដោយប្រើប្រាស់តាមវិធីសាស្ត្របែបបរិមាណវិស័យ។ រាល់ទិន្នន័យដែលប្រមូលបានទាំងអស់ នឹងត្រូវយកមកស្រង់ចូលប្រព័ន្ធ SPSS ដើម្បីវិភាគពន្យល់ដោយមានការប្រៀបធៀបពីទស្សនៈរបស់នាយក លោកគ្រូ អ្នកគ្រូ ការវិភាគដោយផ្អែកទៅលើឯកសារទ្រឹស្តីដែលមានរួចមកហើយអំពីការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

## ៣.១០ ក្រមសីលធម៌នៃការស្រាវជ្រាវ

ការសិក្សាសិក្សាស្រាវជ្រាវនេះ ត្រូវបានអនុញ្ញាតដោយក្រសួងអប់រំយុវជន និងកីឡា យោងលិខិតលេខ៤០៨២ អយក.វជអ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាជម្រាបមកមន្ទីរអប់រំ រាជធានីខេត្ត ដើម្បីជួយសម្របសម្រួលលើការចុះប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវរយៈពេល ១ខែកន្លះ។ អ្នកសិក្សាស្រាវជ្រាវបានយកលិខិតនោះ ប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង បន្ទាប់មកមន្ទីរអប់រំ យុវជន និងកីឡាខេត្តបានចារមានចុះលេខអនុញ្ញាតដើម្បីឱ្យអ្នកស្រាវជ្រាវយកទៅតាមសាលាគោលដៅដើម្បីចុះប្រមូលទិន្នន័យ។

ដើម្បីរក្សាក្រមសីលធម៌ក្នុងការស្រាវជ្រាវមុនដំបូងអ្នកស្រាវជ្រាវបានណែនាំខ្លួន និងប្រាប់ពីគោលបំណងក្នុងការចុះប្រមូលប្រមូលទិន្នន័យ និងការសន្យាលើលក្ខខណ្ឌមួយចំនួនដូចជារក្សាការសម្ងាត់ជូនគាត់ ព័ត៌មានដែលទទួលបានមិនត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងៗឡើយ។

# ជំពូក៤

# លទ្ធផល និងការពិភាក្សា

ជំពូកនេះនឹងបង្ហាញពីលទ្ធផល នៃការវិភាគទិន្នន័យលើប្រធានបទ៖ «**ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង**» ការសិក្សាដើម្បីសិក្សាឈ្វេងយល់ថា តើការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀងស្ថិតក្នុងកម្រិតណាមានបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្ត។ លទ្ធផលនៃការវិភាគទិន្នន័យត្រូវបានយកមកបកស្រាយតាមរយៈការបំពេញកម្រងសំណួរទៅលើក្រុមគោលដៅដែលពាក់ព័ន្ធរួមមាន គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន នៅអនុវិទ្យាល័យគោលដៅក្នុងខេត្តស្វាយរៀង។ សូចនាករស្តីពីស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានចំនួន៤សមាសភាគរួមមាន៖ (១)ចំណេះដឹងវិជ្ជាជីវៈ (២)ការប្រតិបត្តិវិជ្ជាជីវៈ (៣)ការសិក្សាវិជ្ជាជីវៈ និង(៤)សីលធម៌វិជ្ជាជីវៈ ហើយសូចនាករសម្រាប់សួរគណៈគ្រប់គ្រងសាលារៀនក៏ជ្រើសរើសយកស្តង់ដាទាំងបួននៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដូចគ្នា។ ត្រង់ន័យនេះគឺចង់ដឹងពីទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងទៅលើការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ពីព្រោះគណៈគ្រប់គ្រងជាអ្នកចុះអធិការកិច្ចជាប្រចាំ ដឹកនាំ គ្រប់គ្រង ដូច្នេះក៏អាចយល់បានស៊ីជម្រៅទៅលើការអនុវត្តរបស់គ្រូបង្រៀនទៅលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ រួមមានស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យនៅតាមសាលាគោលដៅ ថាតើស្ថានភាពនៃនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនស្ថិតនៅក្នុងកម្រិតណានាពេលបច្ចុប្បន្ន ហើយមានបញ្ហាប្រឈមអ្វីខ្លះក្នុងការអនុវត្តនៅក្នុងខេត្តស្វាយរៀង។

## ៤.១ ព័ត៌មានទូទៅ

### ៤.១.១ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀន

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| | | វិទ្យាល័យហ៊ុន សែនចេក | 3 | 15 |
| | | វិទ្យាល័យក្រោលគោ | 3 | 15 |
| | | វិទ្យាល័យស្វាយជ្រំ | 2 | 10 |

| | | | | |
|---|---|---|---|---|
| 1 | **ឈ្មោះសាលា** | វិទ្យាល័យគោកព្រីង | 2 | 10 |
| | | **វិទ្យាល័យស្វាយរៀង** | 4 | 20 |
| | | អនុវិទ្យាល័យបាសាក់ | 2 | 10 |
| | | អនុវិទ្យាល័យតាដៃ | 2 | 10 |
| | | អនុវិទ្យាល័យខ្នាយ | 2 | 10 |
| | | សរុប | 20 | 100.0 |
| 2 | **ភេទ** | ប្រុស | 18 | 90 |
| | | ស្រី | 2 | 10 |
| | | សរុប | 20 | 100.0 |
| 3 | **បទពិសោធគ្រប់គ្រង** | 1 -5 ឆ្នាំ | 0 | 0 |
| | | 6-10 ឆ្នាំ | 10 | 50 |
| | | 11-15 ឆ្នាំ | 6 | 30 |
| | | លើសពី 20 ឆ្នាំ | 4 | 20 |
| | | Total | 20 | 100.0 |
| 4 | **កម្រិតវប្បធម៌** | បឋមភូមិ | 0 | 0 |
| | | ទុតិយភូមិ | 4 | 20 |
| | | បរិញ្ញាបត្ររង | 0 | 0 |
| | | បរិញ្ញាបត្រ | 16 | 80 |
| | | អនុបណ្ឌិត | 0 | 0 |
| | | សរុប | 20 | 100.0 |
| 5 | **វគ្គបណ្តុះបណ្តាល** | វគ្គនាយកសាលា (វដអ) | 0 | 0 |
| | | វគ្គបណ្តុះបណ្តាលនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ | 4 | 20 |
| | | វគ្គបំប៉នផ្សេងៗ | 16 | 80 |
| | | សរុប | 20 | 100.0 |
| 6 | **ទីតាំងសាលា** | ក្រុង | 7 | 35 |
| | | ជនបទ | 13 | 65 |
| | | សរុប | 16 | 100.0ភាគរយ |

តាមទិន្នន័យដែលទទួលបានពីគណៈគ្រប់គ្រងសាលារៀនបានបង្ហាញថាគណៈគ្រប់គ្រងនៅវិទ្យាល័យក្រោលគោចំនួន០៣នាក់ ស្មើនឹង១៥ភាគរយ គណៈគ្រប់គ្រងនៅវិទ្យាល័យស្វាយជ្រុំមានចំនួន០២នាក់ស្មើនឹង១០ភាគរយ គណៈគ្រប់គ្រងនៅវិទ្យាល័យស្វាយរៀងមានចំនួន០៤នាក់ ស្មើនឹង២០ភាគរយ

គណៈគ្រប់គ្រងនៅវិទ្យាល័យជំនាន់ថ្មីគោកព្រីងចំនួន០២នាក់ ស្មើនឹង១០ភាគរយ គណៈគ្រប់គ្រងនៅវិទ្យាល័យហ៊ុនសែនចេក ចំនួន០៣នាក់ ស្មើនឹង១៥ភាគរយ គណៈគ្រប់គ្រងនៅអនុវិទ្យាល័យបាសាក់ខ្នាយ និងតាដៃ មានចំនួន០២នាក់ស្មើគ្នា ត្រូវនឹង១០ភាគរយ។ គណៈគ្រប់គ្រងសាលាដែលមានទីតាំងនៅក្នុងក្រុងមានចំនួន០៧នាក់ ស្មើនឹង៣៥ភាគរយ និង គណៈគ្រប់គ្រងសាលាដែលមានទីតាំងនៅជនបទមានចំនួន១៣នាក់ស្មើនឹង៦៥ភាគរយ។ គណៈគ្រងគ្រងមានបទពិសោធគ្រប់គ្រងចាប់ពីចន្លោះ ០៦ឆ្នាំ ទៅ១០ ឆ្នាំមានចំនួន១០នាក់ស្មើនឹង៥០ភាគរយ បទពិសោធគ្រប់គ្រងចាប់ពីចន្លោះពី ១១ឆ្នាំ ទៅ ១៥ឆ្នាំមានចំនួន០៦នាក់ស្មើនឹង៣០ភាគរយ និងបទពិសោធគ្រប់គ្រងលើសពី២០ឆ្នាំ មានចំនួន០៤នាក់ស្មើនឹង២០ភាគរយ ។

គណៈគ្រប់គ្រងដែលមានសញ្ញាបត្រទុតិយភូមិមានចំនួន០៤នាក់ស្មើនឹង២០ភាគរយ គណៈគ្រប់គ្រងដែលមានសញ្ញាបត្របរិញ្ញាបត្រមានចំនួន១៦នាក់ស្មើនឹង៨០ភាគរយ។ គណៈគ្រប់គ្រងដែលបានចូលរួមវគ្គបណ្ដុះបណ្ដាលនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញមានចំនួន ០៤នាក់ស្មើនឹង ២០ភាគរយ និង គណៈគ្រប់គ្រងដែលបានចូលរួមវគ្គបណ្ដុះបណ្ដាលវគ្គបំប៉នផ្សេងៗមានចំនួន១៦នាក់ ស្មើនឹង៨០ភាគរយ។

### ៤.១.២ ព័ត៌មានទូទៅរបស់គ្រូបង្រៀន

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| 1 | ឈ្មោះសាលា | វិទ្យាល័យក្រោលគោ | 11 | 12.21 |
| | | វិទ្យាល័យស្វាយជ្រំ | 20 | 22.2 |
| | | វិទ្យាល័យគោកព្រីង | 10 | 11.1 |
| | | វិទ្យាល័យហ៊ុន សែនចេក | 20 | 22.2 |
| | | អនុវិទ្យាល័យបាសាក់ | 10 | 11.1 |
| | | អនុវិទ្យាល័យតាដៃ | 10 | 11.1 |
| | | អនុវិទ្យាល័យខ្នាយ | 10 | 11.1 |
| | | វិទ្យាល័យស្វាយរៀង | 20 | 22.2 |
| | | សរុប | 111 | 100 |
| 2 | ភេទ | ប្រុស | 64 | 57.7 |

| | | | | |
|---|---|---|---|---|
| | | ស្រី | 47 | 42.3 |
| | | សរុប | 111 | 100 |
| 3 | អាយុ | 20-30ឆ្នាំ | 22 | 19.8 |
| | | 31-40ឆ្នាំ | 33 | 29.7 |
| | | លើសពី41ឆ្នាំ | 56 | 50.5 |
| | | **សរុប** | 111 | 100 |
| 4 | កម្រិតវប្បធម៌ | បឋមភូមិ | 9 | 8.1 |
| | | ទុតិយភូមិ | 53 | 47.7 |
| | | បរិញ្ញាបត្ររង | 1 | .9 |
| | | បរិញ្ញាបត្រ | 45 | 40.5 |
| | | អនុបណ្ឌិត | 3 | 2.7 |
| | | សរុប | 111 | 100.0 |
| 5 | វគ្គបណ្ដុះបណ្ដាល | 7+3 | 19 | 17.1 |
| | | 8+3 | 5 | 4.5 |
| | | 11+3 | 2 | 1.8 |
| | | 12+2 | 79 | 71.2 |
| | | 12+4 | 1 | .9 |
| | | វគ្គពន្លឿន | 5 | 4.5 |
| | | សរុប | 111 | 100 |
| 6 | បង្រៀនថ្នាក់ទី | ថ្នាក់ទី 7 | 26 | 23.4 |
| | | ថ្នាក់ទី 8 | 29 | 26.1 |
| | | ថ្នាក់ទី9 | 45 | 40.5 |
| | | 2 កម្រិតថ្នាក់ | 6 | 5.4 |
| | | 3 កម្រិតថ្នាក់ | 5 | 4.5 |
| | | សរុប | 111 | 100 |
| 7 | វគ្គសិក្សាខ្លីៗ | គម្រោងGEIP | 11 | 9.9 |
| | | ការគ្រប់គ្រងការបង្រៀននិងរៀន | 13 | 11.7 |
| | | ការរៀបចំតេស្តស្តង់ដា | 19 | 17.1 |
| | | វគ្គICT | 11 | 9.9 |
| | | វគ្គបំប៉នសិក្ខាសាលាផ្សេងៗ | 10 | 9.0 |
| | | មិនដែល | 47 | 42.3 |
| | | សរុប | 111 | 100.0 |

តាមទិន្នន័យដែលទទួលបានពីគ្រូបង្រៀនបានបង្ហាញថាគ្រូបង្រៀននៅវិទ្យាល័យក្រោលគោចំនួន ០១នាក់ ស្មើនឹង០.៩ភាគរយ គ្រូបង្រៀននៅវិទ្យាល័យស្វាយជ្រំ មានចំនួន៣២នាក់ស្មើនឹង២៩.៤ភាគរយ គ្រូបង្រៀននៅវិទ្យាល័យជំនាន់ថ្មីគោកព្រីងចំនួន២០នាក់ស្មើនឹង១៨.៣ភាគរយ គ្រូបង្រៀននៅវិទ្យាល័យហ៊ុនសែនចេក ចំនួន៣០នាក់ស្មើនឹង២៧.៥ភាគរយ គ្រូបង្រៀននៅអនុវិទ្យាល័យបាសាក់ចំនួន៣នាក់ស្មើនឹង២.៨ភាគរយ គ្រូបង្រៀននៅអនុវិទ្យាល័យតាដែមានចំនួន១១នាក់ស្មើនឹង១០.១ភាគរយ និងគ្រូបង្រៀននៅអនុវិទ្យាល័យខ្នាយមានចំនួន១២នាក់ស្មើនឹង១១ភាគរយ។ គ្រូបង្រៀនដែលជាភេទប្រុសមានចំនួន៦២នាក់ស្មើនឹង៥៦.៩ភាគរយនិងភេទស្រីចំនួន៤៧នាក់ស្មើនឹង៤៣.១ភាគរយ។ ចំពោះគ្រូបង្រៀនដែលមានចន្លោះអាយុពី២០ឆ្នាំទៅ៣០ឆ្នាំមានចំនួន២១នាក់ស្មើនឹង១៩.៣ភាគរយ ចន្លោះអាយុពី៣១ឆ្នាំទៅ៤០ឆ្នាំមានចំនួន៣១នាក់ស្មើនឹង២៨.៤ភាគរយ និងគ្រូបង្រៀនដែលមានអាយុលើសពី៤១ឆ្នាំឡើងមានចំនួន៤៦នាក់ស្មើនឹង៥១.៤ភាគរយ។ គ្រូបង្រៀនដែលមានសញ្ញាបត្របឋមភូមិមានចំនួន៩នាក់ស្មើនឹង៨.៣ភាគរយ គ្រូបង្រៀនដែលមានសញ្ញាបត្រទុតិយភូមិមានចំនួន៥៣នាក់ស្មើនឹង៤៨.៦ភាគរយ គ្រូបង្រៀនដែលមានសញ្ញាបត្របរិញ្ញាបត្ររងមានចំនួន០១នាក់ស្មើនឹង០.៩ភាគរយគ្រូបង្រៀនដែលមានសញ្ញាបត្របរិញ្ញាបត្រមានចំនួន៤៣នាក់ស្មើនឹង៣៩.៤ភាគរយនិងគ្រូបង្រៀនដែលមានសញ្ញាបត្រអនុបណ្ឌិតមានចំនួន០៣នាក់ស្មើនឹង២.៨ភាគរយ។ ការចូលរួមវគ្គបណ្តុះបណ្តាលគ្រូ៧+៣មានចំនួន១៩នាក់ស្មើនឹង១៧.៤ភាគរយ វគ្គបណ្តុះបណ្តាលគ្រូ ៨+៣ មានចំនួន០៤នាក់ស្មើនឹង៣.៧ភាគរយ វគ្គបណ្តុះបណ្តាលគ្រូ ១១+៣ មានចំនួន២នាក់ ស្មើនឹង១.៨ភាគរយ វគ្គបណ្តុះបណ្តាលគ្រូ ១២+២ មានចំនួន៧៨នាក់ ស្មើនឹង៧១.៦ភាគរយ វគ្គបណ្តុះបណ្តាលគ្រូ ១២+៤ មានចំនួន១នាក់ស្មើនឹង០.៩ភាគរយ និងវគ្គបណ្តុះបណ្តាលគ្រូវគ្គពន្លឿនមានចំនួន៥នាក់ស្មើនឹង៤.៦ភាគរយ។ គ្រូដែលបង្រៀននៅថ្នាក់ទី៧មានចំនួន២៦នាក់ ស្មើនឹង២៣.៩ភាគរយ ថ្នាក់ទី៨មានចំនួន២៨នាក់ស្មើនឹង២៥.៧ភាគរយ ថ្នាក់ទី៩មានចំនួន៤៤នាក់ស្មើនឹង៤០.៤ភាគរយ គ្រូដែលបង្រៀនពីរកម្រិតថ្នាក់មានចំនួន៦នាក់ស្មើនឹង៥.៦ភាគរយ និងគ្រូដែលបង្រៀនបីកម្រិតថ្នាក់មានចំនួន៥នាក់ស្មើនឹង៤.៦ភាគរយ។ ចំពោះវគ្គសិក្សាខ្លីៗ គ្រូបាន

ចូលរួមគម្រោងGIEPមានចំនួន១១នាក់ស្មើនឹង១០.១ភាគរយ វគ្គសិក្សាអំពីការគ្រប់គ្រងការបង្រៀននិងរៀនមានចំនួន១៣នាក់ស្មើនឹង១១.៩ភាគរយ វគ្គសិក្សាអំពីការរៀបចំតេស្តស្តង់ដាមានចំនួន១៩នាក់ស្មើនឹង១៧.៤ភាគរយវគ្គសិក្សាICTមានចំនួន១១នាក់ស្មើនឹង១០.១ភាគរយវគ្គបំប៉នសិក្ខាសាលាផ្សេងៗមានចំនួន១០នាក់ស្មើនឹង៩.២ភាគរយនិងមិនដែលចូលរួមវគ្គសិក្សាខ្លីៗមានចំនួន៤៥នាក់ស្មើនឹង៤១.៣ភាគរយ។

ដូចនេះទិន្នន័យដែលទទួលបានបានបញ្ជាក់ថាកម្រិតចំណេះដឹង និងគុណវុឌ្ឍិគ្រូបង្រៀន បានជះឥទ្ធិពលដល់ការយល់ឃើញលើស្ថានភាពនៃភាពជាអ្នកដឹកនាំរបស់គ្រូ ជាពិសេសលើការឆ្លើយតបទៅនឹងសូចនាករនីមួយៗដែលបានវាស់វែង។ ជាងនេះទៅទៀត វាក៏បានជះឥទ្ធិពលើការបង្រៀនរបស់ពួកគាត់ផ្ទាល់ និងការរៀនរបស់សិស្សផងដែរ។ តែទោះបីជាយ៉ាងណាក៏ដោយ ពួកគាត់មានបំណិនវិជ្ជាជីវៈ មានបទពិសោធន៍នៃការបំពេញការងារយូរឆ្នាំ និងមានវិន័យ និងក្រមសីលធម៌វិជ្ជាជីវគ្រូបង្រៀន ដែលកត្តាទាំងនេះ ធ្វើឱ្យទិន្នន័យដែលយើងប្រមូលបាននៅតែមានភាពត្រឹមត្រូវអាចទទួលយកបាន។ ការបង្រៀនដែលមានបទពិសោធន៍ការងារយូរឆ្នាំ ពួកគាត់អាចកំណត់បាននូវស្ថានភាពអនុវត្តមួយច្បាស់លាស់ ហើយអាចធ្វើការវាយតម្លៃ និងចង្អុលបង្ហាញនូវកម្រិតនៃការអនុវត្តនាពេលកន្លងមក និងក្នុងពេលបច្ចុប្បន្ន។

## ៤ ២.វិភាគលទ្ធផលពីសមាសភាគនៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

**តារាង៤.២.១៖ស្តង់ដាទីមួយ ចំណេះដឹងវិជ្ជាជីវៈ**

| ល.រ | I.ការគ្រប់គ្រងផ្អែកលើចំណេះដឹងឯកទេស | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | ម.ភាគ | គ.ស្តង់ដា | កម្រិត | ម.ភាគ | គ.ស្តង់ដា | កម្រិត |
| ១ | ខ្ញុំមានចំណេះដឹងលើឯកទេសរបស់ខ្ញុំ | 2.91 | 1.19 | មធ្យម | 3.50 | 0.60 | មធ្យម |
| ២ | ខ្ញុំមានចំណេះដឹងលើផ្នែកគោលនយោបាយក្រសួងអប់រំ | 3.86 | 0.75 | ល្អបង្គួរ | 4.25 | 0.63 | ល្អ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ខ្ញុំមានយល់ដឹងអំពីនិន្នាការអប់រំបច្ចុប្បន្នរបស់ក្រសួងអប់រំ( កំណែទម្រង់ ) | 3.37 | 0.76 | មធ្យម | 3.40 | 0.68 | មធ្យម |
| ៤ | ខ្ញុំយល់ដឹងពីកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល | 3.50 | 0.74 | មធ្យម | 3.90 | 0.75 | ល្អបង្គួរ |
| ៥ | ខ្ញុំយលដឹងពីវិធីសាស្ត្របង្រៀនថ្មីៗ | 3.85 | 0.62 | ល្អបង្គួរ | 3.80 | 0.81 | ល្អបង្គួរ |
| ៦ | ខ្ញុំយល់ដឹងពីតេស្តស្តង់ដា | 3.67 | 0.71 | ល្អបង្គួរ | 3.90 | 0.85 | ល្អបង្គួរ |
| ៧ | ខ្ញុំដឹងតម្រូវការសិស្ស សមត្ថភាពសិស្ស ប្រវត្តិសិក្សា និងឥរិយាបទរបស់សិស្ស | 3.46 | 0.68 | មធ្យម | 3.50 | 0.82 | មធ្យម |
| ៨ | ខ្ញុំស្គាល់សុខភាព ជីវភាពគ្រួសារ ចំណង់ចំណូលចិត្តសិក្សារបស់សិស្ស | 3.71 | 0.66 | ល្អបង្គួរ | 3.50 | 0.60 | មធ្យម |
| ៩ | ខ្ញុំដឹងច្បាស់ពី យែនឌ័រ សាវតាសង្គម សេដ្ឋកិច្ច ពិការភាព និងក្រុមជនជាតិភាគតិច) ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងដឹងពីរបៀបដោះស្រាយបញ្ហាទាំងនោះ) | 3.46 | 0.72 | មធ្យម | 3.40 | 0.59 | មធ្យម |
| | សរុប | 3.53 | 0.76 | ល្អបង្គួរ | 3.68 | 0.70 | **ល្អបង្គួរ** |

តាមតារាង ៤.២.១ ខាងលើបង្ហាញថាគ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុបអំពី ការគ្រប់គ្រងផ្អែកលើចំណេះដឹងឯកទេសទទួលបានពិន្ទុយល់ស្របក្នុងកម្រិត «ល្អបង្គួរ» (មធ្យមភាគពិន្ទុ=3.53)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ «គ្រូបង្រៀនយល់ដឹងពិវិធីសាស្ត្របង្រៀនថ្មីៗ» ក្នុងកម្រិត«ល្អ» (មធ្រមភាគពិន្ទុ=៣.៨៥)។ សូចនការដែលទទួលបានពិន្ទុទាបជាងគេគឺ «គ្រូមានចំណេះលើឯកទេសរបស់ខ្លួន» ក្នុងកម្រិត «មធ្យម» (មធ្យមភាគពិន្ទុ=២.៩១)។

គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុបអំពីការគ្រប់គ្រងផ្អែកលើចំណេះដឹងឯកទេសក្នុងកម្រិត «ល្អបង្គួរ» (មធ្យមភាគពិន្ទុ=3.68)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេមានចំនួនពីរគឺៈ «យល់

ដឹងពីកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល» និង«យល់ដឹងពីតេស្តស្តង់ដា» ក្នុងកម្រិត «ល្អបង្គួរ» (មធ្យមភាគពិន្ទុ=3.90)។

**តារាង ៤.២.២ ស្តង់ដាទី២ ការប្រតិបត្តិវិជ្ជាជីវៈ**

| ល.រ | II. ការប្រតិបត្តិវិជ្ជាជីវៈ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | ម.ភាគ | គ.ស្តង់ដា | កម្រិត | ម.ភាគ | គ.ស្តង់ដា | កម្រិត |
| ១ | ខ្ញុំមានបំណែងចែកកម្មវិធីសិក្សា រៀបចំកិច្ចតែងការបង្រៀន និងការវាយតម្លៃលទ្ធផល សិក្សាបានត្រឹមត្រូវហើយមានប្រសិទ្ធភាព | 3.66 | 0.78 | ល្អ | 3.90 | 0.85 | ល្អ |
| ២ | ខ្ញុំរៀបចំសម្ភារបង្រៀន និងរៀន ដើម្បីធ្វើឱ្យការសិក្សារបស់សិស្សសម្រេចបានលទ្ធផលល្អ | 3.64 | 0.64 | ល្អ | 3.10 | 0.55 | មធ្យម |
| ៣ | ខ្ញុំអនុវត្តវិធីសាស្ត្របង្រៀនសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | 3.57 | 0.74 | ល្អ | 3.40 | 0.85 | មធ្យម |
| ៤ | ខ្ញុំចូលរួមប្រជុំក្រុមបច្ចេកទេស (សហគមន៍សិក្សាវិជ្ជាជីវៈជាប្រចាំ) | 3.76 | 0.85 | ល្អ | 4.7 | 0.47 | ល្អណាស់ |
| ៥ | តាមដានការចូលរួម និងថែរក្សាកំណត់ត្រា នៃភាពរីកចម្រើនរបស់សិស្ស | 3.53 | 0.70 | ល្អ | 3.65 | 0.58 | ល្អ |
| ៦ | ខ្ញុំផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស អំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថ របស់សិស្ស | 3.48 | 0.68 | មធ្យម | 3.50 | 0.88 | មធ្យម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧ | ខ្ញុំផ្តល់បរិស្ថានសិក្សាមានសុវត្ថិភាព និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាព | 3.73 | 0.66 | **ល្អ** | **3.85** | **0.81** | **ល្អ** |
| ៨ | ខ្ញុំចូលរួមជាមួយសមាគមន៍មាតាបិតាសិស្ស | 3.32 | 0.71 | **មធ្យម** | **3.50** | **0.76** | **មធ្យម** |
| | សរុប | 3.59 | 0.72 | **ល្អ** | **3.70** | **0.71** | **ល្អ** |

តាមតារាង ៤.២.២ ខាងលើបង្ហាញថាគ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុបអំពី «ការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀន» ក្នុងកម្រិត «ល្អបង្គួរ» (មធ្យមភាគពិន្ទុ=3.59)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ «គ្រូបង្រៀនចូលរួមប្រជុំក្រុមបច្ចេកទេស (សហគមន៍សិក្សាវិជ្ជាជីវៈជាប្រចាំ)» ក្នុងកម្រិត «ល្អបង្គួរ» (មធ្យមភាគ=៣.៧៦)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេ «គ្រូចូលរួមជាមួយសមាគមន៍មាតាបិតាសិស្ស» ក្នុងកម្រិត «ធម្យម» (មធ្យមភាគ=៣.៣២)។

គណៈនាយកបានផ្តល់ទិន្នន័យជាសរុបអំពី «ការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀន» ក្នុងកម្រិត «ល្អបង្គួរ» (មធ្យមភាគពិន្ទុ=3.70)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ «ចូលរួមប្រជុំក្រុមបច្ចេកទេស (សហគមន៍សិក្សាវិជ្ជាជីវៈជាប្រចាំ)» ក្នុងកម្រិត «ល្អ» (មធ្យមភាគពិន្ទុ=4.70)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ «រៀបចំសម្ភារបង្រៀន និងរៀន ដើម្បីធ្វើឱ្យការសិក្សារបស់សិស្សសម្រេចបានលទ្ធផលល្អ» ក្នុងកម្រិត «មធ្យម» (មធ្យមភាគពិន្ទុ=3.10)។

**តារាង ៤.២.៣ ស្តង់ដាទីបី ការសិក្សាវិជ្ជាជីវៈ**

| ល.រ | III. ការសិក្សាវិជ្ជាជីវៈ (ការស្រាវជ្រាវ) | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | ម.ភាគ | គ.ស្តង់ដារ | កម្រិត | ម.ភាគ | គ.ស្តង់ដារ | កម្រិត |
| ១ | ខ្ញុំវាយតម្លៃការបង្រៀន ការអភិវឌ្ឍខ្លួនឯង និងការប្រើប្រាស់ផែនការសម្រាប់ដឹកនាំ ស្វ័យសិក្សាវិជ្ជាជីវៈបានទៀងទាត់ | 3.51 | 0.71 | **ល្អបង្គួរ** | **3.50** | **0.51** | **មធ្យម** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | ខ្ញុំអភិវឌ្ឍចំណេះដឹងបច្ចេកវិជ្ជាព័ត៌មាន និងបំដានអនុវត្តក្នុងការបង្រៀន និងរៀន | 3.58 | 0.79 | **ល្អបង្គួរ** | **3.30** | **0.73** | **មធ្យម** |
| ៣ | ខ្ញុំអភិវឌ្ឍបំណិនទាក់ទង ជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងសហគមន៍របស់ខ្ញុំ | 3.44 | 0.73 | **មធ្យម** | **3.50** | **0.60** | **មធ្យម** |
| ៤ | ខ្ញុំអានអត្ថបទវិជ្ជាជីវៈគ្រូបង្រៀន និងស្រាវជ្រាវ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យធ្វើឱ្យការបង្រៀនរបស់ខ្ញុំកាន់តែប្រសើរឡើង | 3.75 | 0.66 | **ល្អបង្គួរ** | **3.55** | **0.60** | **ល្អបង្គួរ** |
| ៥ | ខ្ញុំចូលរួមជាមួយគ្រូបង្រៀនដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈផ្សេងៗ | 3.70 | 0.73 | **ល្អបង្គួរ** | **3.60** | **0.82** | **ល្អបង្គួរ** |
| ៦ | ខ្ញុំចូលរួមវគ្គបណ្ដុះបណ្ដាលរៀបចំដោយក្រសួងអប់រំ ឬការរៀបចំដោយសាលារបស់ខ្ញុំ | 3.37 | 0.87 | **មធ្យម** | **3.30** | **1.08** | **មធ្យម** |
| ៧ | ខ្ញុំពង្រឹងសមត្ថភាពភាសាបរទេសមានដូចជាភាសាអង់គ្លេស បារាំង | 3.01 | 0.98 | **មធ្យម** | **2.35** | **0.48** | **ខ្សោយ** |
| | សរុប | 3.48 | 0.78 | **មធ្យម** | **3.30** | **0.68** | **មធ្យម** |

តារាង **៤.២.៣** ខាងលើបង្ហាញថាគ្រូបង្រៀនបានផ្ដល់ទិន្នន័យជាសរុបអំពីការសិក្សាវិជ្ជាជីវៈក្នុងកម្រិត «មធ្យម» (មធ្យមភាគពិន្ទុ=3.48)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេ «គ្រូបង្រៀនអានអត្ថបទវិជ្ជាជីវៈគ្រូបង្រៀន និងស្រាវជ្រាវ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យធ្វើឱ្យការបង្រៀនរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង» ក្នុងកម្រិត «ល្អបង្គួរ» (មធ្យមភាគពិន្ទុ=៣.៧៥)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ «គ្រូពង្រឹងសមត្ថភាពភាសាបរទេសមានដូចជាភាសាអង់គ្លេស បារាំង» ក្នុងកម្រិត «មធ្យម» (មធ្យមភាគពិន្ទុ=៣.០១)។

គណៈគ្រប់គ្រងសាលារៀន បានផ្តល់ទិន្នន័យជាសរុបអំពី ការសិក្សាវិជ្ជាជីវៈក្នុងកម្រិត ក្នុងកម្រិត « មធ្យម» (មធ្យមភាគពិន្ទុ=3.30)។ សូចនាការដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ ចូលរួមជាមួយគ្រូបង្រៀនដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈផ្សេងៗ ក្នុងកម្រិត «ល្អបង្គួរ» (មធ្យមភាគពិន្ទុ=3.60)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ ពង្រឹងសមត្ថភាពភាសាបរទេសមានដូចជាភាសាអង់គ្លេស បារាំង ក្នុងកម្រិត «ខ្សោយ» (មធ្យមភាគពិន្ទុ=2.35)។

**តារាង ៤.២.៤ ស្តង់ដាទីបួន សីលធម៌វិជ្ជាជីវៈ**

| ល.រ | VI. **សីលធម៌វិជ្ជាជីវៈ** | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | ម.ភាគ | គ.ស្តង់ដា | កម្រិត | ម.ភាគ | គ.ស្តង់ដា | កម្រិត |
| ១ | ខ្ញុំយកចិត្តទុកដាក់លើការរៀនរបស់សិស្ស និងប្រឹងបង្រៀនដើម្បីប្រយោជន៍សិស្ស និងសង្គម | 3.81 | 0.68 | ល្អបង្គួរ | 4.20 | 0.61 | ល្អ |
| ២ | ខ្ញុំប្តេជ្ញាចិត្តនិងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ | 3.98 | 0.71 | ល្អបង្គួរ | 4.25 | 0.55 | ល្អ |
| ៣ | ខ្ញុំមានអាកប្បកិរិយាល្អ មានសីលធម៌ជាគំរូ មានទំនាក់ទំនងល្អជាមួយសិស្ស និងសហគមន៍ | 4.01 | 0.76 | ល្អ | 4.40 | 0.50 | ល្អ |
| ៤ | ខ្ញុំផ្តល់ភាពយុត្តិធម៌ និងតម្លាភាពក្នុងការប្រព្រឹត្តជាមួយសិស្ស មិត្តរួមការងារ និងសហគមន៍ | 4.03 | 0.73 | ល្អ | 4.35 | 0.48 | ល្អ |
| **សរុប** | | 3.96 | 0.72 | ល្អ | 4.30 | 0.53 | ល្អ |

តារាង **៤.២.៤** បានបង្ហាញថាគ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុបអំពីសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនក្នុងកម្រិត «ល្អបង្គួរ» (មធ្យមភាពពិន្ទុ=3.96)។សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេ «គ្រូបង្រៀនផ្តល់ភាពយុត្តិធម៌ និងតម្លាភាព ក្នុងការប្រព្រឹត្តជាមួយសិស្ស មិត្តរួមការងារ និងសហគមន៍» ក្នុងកម្រិត «ល្អ» (មធ្យមភាគពិន្ទុ=4.03)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ «គ្រូបង្រៀនយក

ចិត្តទុកដាក់លើការរៀនរបស់សិស្ស និងប្រឹងបង្រៀនដើម្បីប្រយោជន៍សិស្ស និងសង្គម» ក្នុងកម្រិត «ល្អ» (មធ្យមភាគពិន្ទុ=៣.៨១)។

គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុបអំពីសីលធម៌វិជ្ជាជីវៈរបស់គ្រូបង្រៀនក្នុងកម្រិត «ល្អ» (មធ្យមភាគពិន្ទុ=4.30)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ «គ្រូបង្រៀនមានអាកប្បកិរិយាល្អ មានសីលធម៌ជាគំរូមានទំនាក់ទំនងល្អជាមួយសិស្ស និងសហគមន៍» ក្នុងកម្រិត«ល្អ»(មធ្យមភាគពិន្ទុ=4.40) ហើយសូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ «គ្រូបង្រៀនយកចិត្តទុកដាក់លើការរៀនរបស់សិស្ស និងប្រឹងបង្រៀនដើម្បីប្រយោជន៍សិស្ស និងសង្គម» ក្នុងកម្រិត «ល្អ» (មធ្យមភាគ=4.20)។

**តារាង ៤.២.៥ លទ្ធផលវិភាគជារួមលើស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូងបង្រៀន**

| ល.រ | សូចនាករ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | | សរុបរួម | | |
|---|---|---|---|---|---|---|---|---|---|---|
| | | មភាគ. | គ.ស្តង់ដារ | កម្រិត | មភាគ. | គ.ស្តង់ដារ | កម្រិត | មភាគ. | គ.ស្តង់ដារ | កម្រិត |
| ១ | ចំណេះដឹងវិជ្ជាជីវៈ | 3.53 | 0.76 | ល្អបង្គួរ | 3.68 | 0.70 | ល្អបង្គួរ | 3.60 | 0.73 | ល្អបង្គួរ |
| ២ | ការប្រតិបត្តិវិជ្ជាជីវៈ | 3.48 | 0.78 | មធ្យម | 3.70 | 0.71 | ល្អបង្គួរ | 3.59 | 0.74 | ល្អបង្គួរ |
| ៣ | ការសិក្សាវិជ្ជាជីវៈ | 3.48 | 0.78 | មធ្យម | 3.30 | 0.68 | មធ្យម | 3.39 | 0.73 | មធ្យម |
| ៤ | សីលធម៌វិជ្ជាជីវៈ | 3.96 | 0.72 | ល្អបង្គួរ | 4.30 | 0.53 | ល្អ | 4.13 | 0.62 | ល្អ |
| **សរុបរួម** | | | | | | | | **3.67** | **070** | **ល្អ** |

លទ្ធផលជារួមបង្ហាញថា ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀងគឺៈ ចំពោះស្តង់ដាទី១ «ចំណេះដឹងវិជ្ជាជីវៈ» លទ្ធផលដែលទទួលបានកម្រិតនៃការអនុវត្តស្តង់ដានេះគឺ «ល្អបង្គួរ» ដែលមានមធ្យមភាគពិន្ទុ=3.60។ ចំពោះស្តង់ដាទី២ «ការប្រតិបត្តិវិជ្ជាជីវៈ» លទ្ធ

ផលជារួមដែលទទួលបាន បានបញ្ជាក់ថា ការអនុវត្តស្តង់ដាទី២ ស្ថិតក្នុងកម្រិត «ល្អបង្គួរ» ដែលមានមធ្យមភាគពិន្ទុ= 3.59។ ចំពោះស្តង់ដាទី៣ «ការសិក្សាវិជ្ជាជីវៈ» លទ្ធផលនៃការអនុវត្តគឺស្ថិតក្នុងកម្រិត « មធ្យម» ដែលមានតម្លៃមធ្យមភាគពិន្ទុរួម= 3.៣៩។ និងចំពោះសូចនាករទី៤ «សីលធម៌វិជ្ជាជីវៈ» លទ្ធផលជារួមនៃការអនុវត្តគឺស្ថិតក្នុងកម្រិត «ល្អ» ដែលមានមធ្យមភាគពិន្ទុ=4.13។

សរុបជារួមបានមកពីលទ្ធផលស្រាវជ្រាវបានបង្ហាញថា ការអនុវត្តស្តង់ដាសីលធម៌វិជ្ជាជីវៈ ស្ថិតក្នុងកម្រិត «ល្អ» ដែលនេះបញ្ជាក់បានថា ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនទទួលបានលទ្ធផលល្អ ហើយសូចនាករដែលគួរត្រូវយកចិត្តទុកដាក់បន្ត និងគាំទ្របន្ថែមពីគ្រប់ភាគីពាក់ព័ន្ធគឺ ស្តង់ដាទី៣ «ការសិក្សាវិជ្ជាជីវៈ» ដែលស្ថិតក្នុងកម្រិត «មធ្យម» មានមធ្យមភាគពិន្ទុ=3.39។ តាមលទ្ធផលស្រាវជ្រាវបង្ហាញថាគ្រូបង្រៀនត្រូវស្វ័យសិក្សាជាប្រចាំ វាយតម្លៃការបង្រៀនដើម្បីអភិវឌ្ឍខ្លួនឯង និងប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាមុខវិជ្ជាជីវៈជាប្រចាំស្របតាមជីវភាពរស់នៅជាក់ស្តែង។ គ្រូបង្រៀនត្រូវអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស មាតា បិតា មិត្តរួមអាជីព និងជាមួយអ្នកផ្សេងៗទៀតក្នុងសហគមន៍ដើម្បីពង្រឹង និងពង្រីកចំណេះដឹងឱ្យកាន់តែទូលំទូលាយ។

**ផ្នែកទី២៖ បញ្ហាប្រឈមនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន**

| ស្តង់ដា | បញ្ហាប្រឈម |
|---|---|
| ១. ការគ្រប់គ្រងផ្នែកលើការគ្រប់គ្រងលើចំណេះដឹងឯកទេស | – កម្រិតយល់ដឹងលើឯកទេស<br>– មិនសូវយល់ដឹងពីគោលនយោបាយ និងនិន្នាការអប់រំបច្ចុប្បន្ន<br>– គ្រូបង្រៀនទើបតែចេញថ្មី ឬទើបផ្លាស់ទទួលថ្មី<br>– មិនយល់ដឹងពីស្ថានភាពគ្រួសាររបស់សិស្ស<br>– ខ្វះខាតពេលវេលាស្រាវជ្រាវរបស់ខ្លួនឯងផ្ទាល់ (២)<br>– កម្មវិធីសិក្សាខ្វះគ្រូពុំទទួលបានបន្តបំប៉នលើចំណេះដឹងឯកទេស<br>– ខ្វះចំណេះដឹង ICT ក្នុងការសិក្សាស្រាវជ្រាវ (២)<br>– គ្រូបង្រៀនភាគច្រើនពុំបានបន្តការសិក្សាបន្ថែមលើឯកទេសរបស់ខ្លួន |
| ២. ការប្រតិបត្តិវិជ្ជាជីវៈ | – ការផ្តល់ព័ត៌មានត្រឡប់ទៅអាណាព្យាបាលសិស្ស<br>– ការចូលរួមជាមួយសហគមន៍ |

| | |
|---|---|
| | –ការតាមដានការរីកចម្រើនរបស់សិស្ស<br>–ខ្វះខាតបន្ទប់សិក្សា អគារទ្រុឌទ្រោម<br>–បញ្ហាសុខភាព គ្រូចាស់ៗគិតលើសុខភាពច្រើនជាងការងារផ្សេងទៀត<br>–គ្រូបង្រៀនភាគច្រើនមិនសូវចេះផលិតសម្ភារៈបង្រៀន<br>–គ្រូបង្រៀនមួយចំនួនមិនបានប្រើប្រាស់វិធីសាស្ត្របង្រៀនសំបូរបែប<br>–គ្រូខ្លះពុំបានសិក្សាឱ្យបានទូលំទូលាយ<br>–ការអនុវត្តការងារមួយចំនួននៅមានកម្រិតដោយផ្អែកលើបញ្ហាជីវភាពគ្រួសារ |
| ៣. ការសិក្សាវិជ្ជាជីវៈ<br>(ការស្រាវជ្រាវ) | –ខ្វះការសិក្សាបន្ថែមលើភាសាបរទេស<br>–ការអភិវឌ្ឍបំណិនទំនាក់ទំនង<br>–ផែនការអភិវឌ្ឍវិជ្ជាជីវៈស្វ័យសិក្សាឱ្យបានទៀងទាត់ |
| ៤. សីលធម៌វិជ្ជាជីវៈ | –គ្រូសិស្សនិងសហគមន៍មិនសូវមានទំនាក់ទំនងល្អ |

## ៤.៣ បញ្ហាប្រឈមក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

ស្តង់ដាទីមួយ «ចំណេះដឹងវិជ្ជាជីវៈ» តាមទិន្នន័យដែលទទួលបានពីគ្រូបង្រៀន និងគណៈគ្រប់គ្រងបានបង្ហាញថាគ្រូបង្រៀន មិនសូវយល់ដឹងពីគោលនយោបាយ និងនិន្នាការអប់រំបច្ចុប្បន្ន ជាពិសេសគោលនយោបាយអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ។ គ្រូបង្រៀនទើបចេញថ្មីមិនមានបទពិសោធន៍ច្រើនក្នុងការយល់ដឹងពីទ្រឹស្តីនៃការរៀបចំកិច្ចតែងការបង្រៀន ដូចជា វត្ថុបំណង វិធីសាស្ត្របង្រៀន និងវាយតម្លៃសិក្សាបានសមស្រប។ គ្រូបង្រៀនពុំបានស្វែងយល់ពីស្ថានភាពគ្រួសាររបស់សិស្ស ប្រវត្តិសិក្សារបស់សិស្ស និងឥរិយាបថសិក្សារបស់សិស្ស។ គ្រូបង្រៀនបានចំណាយពេលវេលាតិចតួចក្នុងការសិក្សាស្រាវជ្រាវលើឯកទេសវិជ្ជាជីវៈ និងពុំបានចូលរួមវគ្គបណ្តុះបណ្តាលបន្ថែមលើចំណេះដឹងឯកទេសរបស់ខ្លួន។

ស្តង់ដាទីពីរ «ការប្រតិបត្តិវិជ្ជាជីវៈ» តាមទិន្នន័យដែលទទួលបានបង្ហាញថា គ្រូបង្រៀនពុំសូវប្រើប្រាស់វិធីសាស្ត្របង្រៀនសំបូរបែបក្នុងការបង្រៀនរបស់ខ្លួន។ ម្យ៉ាងទៀតគ្រូបង្រៀនពុំមានសមត្ថភាពគ្រប់

គ្រាន់ក្នុងការផ្តល់ជាមធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈការអនុវត្តវិធីបង្រៀនសមស្របសំបូរបែបដោយពុំបានបង្កើតឱកាសឱ្យសិស្សចូលរួមគិតបានល្អិតល្អន់ និងដោយច្នៃប្រតិដ្ឋ។ លើសពីនេះទៀតគ្រូបង្រៀនមិនសូវចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យ ដើម្បីឱ្យការបង្រៀន និងរៀនមានប្រសិទ្ធភាព។

ស្តង់ដាទីបី «ការសិក្សាវិជ្ជាជីវៈ» តាមទិន្នន័យដែលទទួលបានខាងលើបង្ហាញថា គ្រូបង្រៀនមិនបានសិក្សាបន្ថែមលើចំណេះដឹងភាសាបរទេស បច្ចេកវិទ្យា ព័ត៌មាន សារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន។ គ្រូបង្រៀនមិនបានលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការអាន និងស្រាវជ្រាវ ប្រភពឯកសារផ្សេងៗដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលំអការបង្រៀន និងរៀន។

ស្តង់ដាទីបួន «សីលធម៌វិជ្ជាជីវៈ» តាមទិន្នន័យដែលទទួលបានស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនស្ថិតក្នុងកម្រិតល្អ។

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវលើប្រធានបទ «ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀង» មានគោលបំណងសិក្សាឈ្វេងយល់អពីស្ថានភាពនៃការអនុវត្តការចូលរួមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងបញ្ហាប្រឈមនៃការអនុវត្ត។ ជាការសន្និដ្ឋាន អ្នកស្រាវជ្រាវបានរកឃើញថា ការអនុវត្តស្តង់ដាទាំងបួនលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនគឺៈ (១) ស្តង់ដាទីមួយ ចំណេះដឹងវិជ្ជាជីវៈ មានការអនុវត្តស្ថិតក្នុងកម្រិត «ល្អបង្គួរ» (២) ស្តង់ដាទីពីរ ការប្រតិបត្តិវិជ្ជាជីវៈមានការអនុវត្តស្ថិតក្នុងកម្រិត «ល្អបង្គួរ» (៣) ស្តង់ដាទីបី ការសិក្សាវិជ្ជាជីវៈ មានការអនុវត្តស្ថិតក្នុងកម្រិត «មធ្យម» និង (៤) ស្តង់ដាទីបួនសីលធម៌វិជ្ជាជីវៈ មានការអនុវត្តស្ថិនក្នុងកម្រិត «ល្អ»។ ហើយលទ្ធផលជារួមនៃស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន នៅអនុវិទ្យាល័យក្នុងខេត្តស្វាយរៀងស្ថិតក្នុងស្ថានភាពល្អ។

ការស្រាវជ្រាវនេះក៏បានរកឃើញនូវបញ្ហាប្រឈមក្នុងការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនគឺលើស្ថានភាពនៃការអនុវត្តលើស្តង់ដាទីបីគឺ គ្រូបង្រៀនមិនបានសិក្សាបន្ថែមលើចំណេះដឹងភាសាបរទេស បច្ចេកវិទ្យា ព័ត៌មាន សារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន។ គ្រូបង្រៀនមិនបានលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការអាន និងស្រាវជ្រាវ ប្រភពឯកសារផ្សេងៗដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលំអការបង្រៀន និងរៀន។ ដូចនេះការអនុវត្តស្តង់ដាទីបីពុំទាន់មានប្រសិទ្ធភាពបាននៅឡើយ ដែលទាមទារគ្រូបង្រៀនខ្លួនឯងផ្ទាល់បន្តខិតខំសិក្សាស្រាវជ្រាវបន្ថែមលើវិជ្ជាជីវៈរបស់ខ្លួនដើម្បីកែប្រែខ្លួនទៅជាគ្រូបង្រៀនដែលមានគុណភាព និងជួយដល់លើកកម្ពស់លទ្ធផលសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលល្អ។ ម្យ៉ាងវិញទៀត លទ្ធផលនេះជួយឱ្យគ្រប់ភាគីពាក់ព័ន្ធចូលរួមលើកទឹកចិត្ត និងគាំទ្រធ្វើយ៉ាងណាឱ្យគ្រូបង្រៀនអាចអនុវត្តបាននូវស្តង់ដាទីបីនេះឱ្យកាន់តែល្អប្រសើរថែមទៀត។

## ៥.២ សំណូមពរ

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបង្ហាញអ្នកពាក់ព័ន្ធទាំងអស់ឱ្យដឹងថា ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនស្ថិតក្នុងកម្រិតល្អ ប៉ុន្តែក៏នៅមានសូចនាកររងមួយចំនួននៅមិនទាន់បានអនុវត្តល្អនៅឡើយ។ ស្ថានភាពនៃការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ក៏គួរត្រូវបានយកចិត្តទុកដាក់ ជួយគាំទ្រ ពិនិត្យតាមដាន បន្ថែមទៀតពីគ្រប់ភាគីពាក់ព័ន្ធរួមមាន រដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងគណៈគ្រប់គ្រងដើម្បីជួយគាំទ្រទាំងផ្នែកស្មារតី ថវិកា បច្ចេកទេស ដើម្បីឱ្យគ្រូបង្រៀននៅកម្រិតធម្យមសិក្សាបឋមភូមិអាចអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនបាល្អប្រសើរ ហើយនៅពេលដែលគ្រូបង្រៀនអាចអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនបានល្អប្រសើរ នោះគ្រូបង្រៀននឹងក្លាយជាគ្រូបង្រៀនដែលមានគុណភាព មានចំណេះដឹងពេញលេញ ទាន់សម័យ ដែលអាចឆ្លើយតបទៅនឹងតម្រូវការរៀន និងបង្រៀននាសម័យកាលដ៏រីកចម្រើនយ៉ាងឆាប់រហ័សនេះ និងជួយដល់លទ្ធផលសិក្សារបស់សិស្សមានការរីកចម្រើន ហើយនិយាយជារួមគឺ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះ នឹងនៅតែជាមាគ៌ាដ៏ល្អប្រសើរសម្រាប់គ្រូបង្រៀនក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនពេញមួយជីវិត ដើម្បីជួយលើកកម្ពស់គុណភាពវិស័យអប់រំឱ្យមានភាពរីកចម្រើន ព្រោះគ្រូបង្រៀនជាតួអង្គសំខាន់មួយដែលនៅកៀកផ្ទាល់ជាមួយសិស្ស ផ្ទេរចំណេះដឹងដល់សិស្ស បណ្តុះឥរិយាបទល្អដល់សិស្ស ផ្តល់ចំណេះជំនាញមួយពេញលេញដល់សិស្ស។

## ៥.៣ អនុសាសន៍

